# ក

# មាតិកា

## I- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ០១-១២-២០០០ | -អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីការបង្វែរឥណទាន | ១៨៦៣ |
| ០១-១២-២០០០ | -អនុក្រឹត្យលេខ ៨៨ អនក្រ.បក ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយជើងអ្គី | ១៨៦៥ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៨៩ អនក្រ.បក ស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច | ១៨៦៩ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៩០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៨៧៣ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៩១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៨៧៥ |
| ០៦-១២-២០០០ | -អនុក្រឹត្យលេខ ៩២ អនក្រ.បក ស្តីពីការផ្តល់ឥណទានថវិកា បន្ថែមលើឥណទានថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ | ១៨៧៦ |
| ០៦-១២-២០០០ | -អនុក្រឹត្យលេខ ៩៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៨៧៧ |
| ០៦-១២-២០០០ | -អនុក្រឹត្យលេខ ៩៤ អនក្រ.បក ស្តីពីការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា | ១៨៧៩ |
| ០៦-១២-២០០០ | -អនុក្រឹត្យលេខ ៩៥ អនក្រ.បក ស្តីពីការកែសំរួលរចនាសម្ព័ន្ធសមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | ១៨៨៨ |
| ០១-១២-២០០០ | -អនុក្រឹត្យលេខ ៣៩៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៨៩៣ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៣៩៧ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនសម្ព័ន្ធចំរុះ កាំមីនថៃល | ១៨៩៣ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៣៩៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៨៩៥ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៣៩៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩០០ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៤០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩០១ |

| | | |
|---|---|---|
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៤០១ អនក្រ.តត ស្តីពីការផ្តល់គ្រឿងឥស្សរិយយសជូនមេដាយស្ថាបនាជាតិ | ១៩០២ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៤០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩០៣ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៤០៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៩០៤ |
| ០៤-១២-២០០០ | -អនុក្រឹត្យលេខ ៤០៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៩០៥ |
| ០៧-១២-២០០០ | -អនុក្រឹត្យលេខ ៤០៥ អនក្រ.តត ស្តីពីការតែងតាំងសមាជិក នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី | ១៩០៦ |
| ០៧-១២-២០០០ | -អនុក្រឹត្យលេខ ៤០៦ អនក្រ.តត ស្តីពីការតែងតាំងសមាជិក នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច | ១៩០៧ |
| ០៧-១២-២០០០ | -អនុក្រឹត្យលេខ ៤០៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៩០៩ |


## ២-សេចក្តីសំរេច


| | | |
|---|---|---|
| ០៤-១២-២០០០ | -សេចក្តីសំរេចលេខ ៦៥ សសរ ស្តីពីការបង្កើតលេខាធិការដ្ឋាន របស់គណៈកម្មការចំរុះអន្តរក្រសួងដើម្បីតាមដាន និងបង្ក្រាបក្រុមភេរវកម្មប្រដាប់អាវុធ | ១៩១១ |


## II- ភាគរាជបណ្ណាក្រសួង

## ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាស


| | | |
|---|---|---|
| ០១-១២-២០០០ | -ប្រកាសលេខ ៨៣៧ សហវ ស្តីពីការកំណត់ប្រភេទទំនិញ និងកំរៃសេវាត្រួតពិនិត្យ ទំនិញនាំចេញ នាំចូលផ្ទុកក្នុងកុងតឺន័រ តាមប្រព័ន្ធ TC SCAN | ១៩១៥ |

# I- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៨៧ អនក្រ.បក
### ស្តីពីការបង្វែរឥណទាន

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស-៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នរ/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានចំណាយទៅតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- បានឃើញលិខិតលេខ ៥០៩ សន.ថហ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០០ របស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតអោយបង្វែរឥណទានថវិកាចំនួន ៦.៣៧០.៤៦២.៤២៥ រៀល (ប្រាំមួយពាន់បីរយចិតសិបលានបួនរយហុកសិបពីរពាន់បួនរយម្ភៃប្រាំរៀលគត់) ពីជំពូក១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈនិងការជួសជុលតូច) ទៅជំពូក១៣ (សកម្មភាព នៃកម្មវិធី) របស់មន្ទីរសុខាភិបាល ខេត្ត ក្រុង នៃក្រសួងសុខាភិបាល សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដូចខាងក្រោម ៖

ឯកតាគិតរៀល

| ល.រ | ខេត្ត-ក្រុង | ជំពូក | ឥណទានដើមឆ្នាំ | ការប្រែប្រួលឥណទាន | | ស្ថានភាព ឥណទានថ្មី |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| ១ | កំពង់ចាម | 11 | 3.700.000.000 | - | 2.419.089.155 | 1.280.910.845 |
| | | 13 | | 2.419.089.155 | - | 2.419.089.155 |
| ២ | សៀមរាប | 11 | 1.660.000.000 | - | 1.357.652.900 | 302.347.100 |
| | | 13 | | 1.357.652.900 | - | 1.357.652.900 |
| ៣ | កំពង់ធំ | 11 | 1.287.000.000 | - | 1.011.487.300 | 275.512.700 |
| | | 13 | | 1.011.487.300 | - | 1.011.487.300 |
| ៤ | ពោធិសាត់ | 11 | 638.000.000 | - | 375.481.200 | 262.518.800 |
| | | 13 | | 375.481.200 | | 375.481.200 |
| ៥ | កំពង់ឆ្នាំង | 11 | 1.030.000.000 | - | 550.348.100 | 479.651.900 |
| | | 13 | | 550.348.100 | - | 550.348.100 |
| ៦ | ក្រុងព្រះសីហនុ | 11 | 450.000.000 | - | 373.742.670 | 76.257.330 |
| | | 13 | | 373.742.670 | - | 373.742.670 |
| ៧ | ស្ទឹងត្រែង | 11 | 427.000.000 | - | 282.661.100 | 144.338.900 |
| | | 13 | | 282.661.100 | - | 282.661.100 |
| | សរុប | 11 | 9.192.000.000 | - | 6.370.462.425 | 282.1537.575 |
| | | 13 | | 6.370.462.425 | - | 6.370.462.425 |

**មាត្រា ២ .-** ឥណទានថវិកាក្នុងមាត្រា ១ ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ របស់មន្ទីរសុខាភិបាលខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តពោធិសាត់ ខេត្តកំពង់ឆ្នាំង ក្រុងព្រះសីហនុ និងខេត្តស្ទឹងត្រែង នៃក្រសួងសុខាភិបាល សំរាប់ចំណាយលើការងារកម្មវិធីសកម្មភាពជាអាទិភាពសំរាប់ឆមាសទី២ ឆ្នាំ ២០០០ ។

**មាត្រា ៣ .-** ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្ត

អនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៨៨ អនក្រ.បក

## ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

## សំរេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១ ._

ត្រូវបានបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី សំរាប់ជំនួយការ ក្នុងការប្រតិបត្តិបេសកកម្មរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងវិស័យដីធ្លី ។ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានទីតាំងស្ថិតនៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

### ជំពូកទី ២

### បេសកកម្ម និង សមាសភាព

មាត្រា ២ ._

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានបេសកកម្មផ្តួចផ្តើមជំរុញដាក់អោយដំណើរការ និងតាមដានការអនុវត្តន៍គោលនយោបាយ និងកម្មវិធីការងារដីធ្លី ស្របតាមការតម្រង់ទិសរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

មាត្រា ៣ ._

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានមុខងារ និងភារកិច្ចដូចតទៅ :

១-ផ្តួចផ្តើម និងលើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគំរោងផែនការកម្មវិធីការងារ និងយុទ្ធសាស្ត្រសំរាប់ធ្វើអោយសំរេចគោលដៅទាំងឡាយនៃការរៀបចំ ការគ្រប់គ្រង និងការបែងចែកដីធ្លី ។

២-អនុវត្តសេចក្តីណែនាំដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការដាក់អោយដំណើរការយុទ្ធសាស្ត្រ និង កម្មវិធីការងារដីធ្លី ។

៣-ចេញសេចក្តីសំរេច និងសេចក្តីណែនាំដល់ ក្រសួង ស្ថាប័ន ខេត្ត ក្រុង ក្នុងការដាក់អោយដំណើរការកម្មវិធីការងារដីធ្លីក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ។

៤-សំរបសំរួលសកម្មភាពនានារបស់ក្រសួង ស្ថាប័នទាំងឡាយដែលទាក់ទងទៅនឹងកម្មវិធីការងារដីធ្លី ។

៥-លើកសំណើគោលនយោបាយដីធ្លី ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ដើម្បីសុំការសំរេច ។

៦-លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគំរោងច្បាប់ លិខិតបទដ្ឋាន និងវិធានការទាំងឡាយដែលទាក់ទងនឹងកិច្ចដំណើរការការងារដីធ្លី ។

៧-សំរបសំរួលមធ្យោបាយរបស់រដ្ឋ និងជំនួយអន្តរជាតិសំរាប់ប្រើប្រាស់ ក្នុងការងារដីធ្លី ។

៨-ដឹកនាំ និងគ្រប់គ្រងការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅ ជាពិសេសអំពីការងារដីធ្លី ។

៩-ធ្វើរបាយការណ៍ជាប្រចាំជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋអំពីលទ្ធផលនៃការងារដីធ្លី ។

មាត្រា ៤ ._

ក្រុមប្រឹក្សាកំណែទំរង់ដីធ្លី មានសមាសភាពដូចតទៅ :

| | |
|---|---|
| -រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| -រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| -រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |

-រដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិកអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

| | |
|---|---|
| -រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងពត៌មាន | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| -រដ្ឋលេខាធិការ នៃក្រសួងផែនការ | ជាសមាជិក |
| -អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| -អគ្គលេខាធិការ នៃគណៈកម្មការវិនិយោគកម្ពុជា | ជាសមាជិក |

មាត្រា ៥ ._

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវ បំពេញមុខការទាំងឡាយរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានចែងក្នុងមាត្រាខាងលើ និងយកចិត្តទុកដាក់ធ្វើអោយដំណើរការការងារដីធ្លីប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព

-អញ្ជើញសមាជិកចូលរួមប្រជុំ កំណត់របៀបវារៈនៃការប្រជុំនានា របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ដឹកនាំការពិភាក្សា និងចេញសេចក្តីសំរេចនានា

-អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនដែលមានសមត្ថភាពជំនាញមកចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-មានសិទ្ធិចុះហត្ថលេខាទ្វេភាគី និងពហុភាគីលើគ្រប់កិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន និងគ្រប់កិច្ចសន្យា ឬអត្ថបទគតិយុត្តដែលទាក់ទងទៅនឹងការងារដីធ្លី

-មានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

មាត្រា ៦ ._

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសិទ្ធិលើកសំណើតែងតាំងតាមករណីចាំបាច់ អ្នកជំនាញការជាតិ និងអន្តរជាតិ ហើយនិងឥស្សរជន ឬមន្ត្រីរាជការជាន់ខ្ពស់ ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាលបច្ចេកទេស ជាទីប្រឹក្សាបច្ចេកទេស ដើម្បីសិក្សាវិភាគ ធ្វើទស្សនទាន ឬផែនការកម្មលើការងារដីធ្លី និងលើកសំណើជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី នូវគំរោងការងារ ដីធ្លីដែលត្រូវដាក់អោយអនុវត្ត ។

## ជំពូកទី ៣

## អគ្គលេខាធិការដ្ឋាន

មាត្រា ៧ ._

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

អគ្គលេខាធិការមាន អគ្គលេខាធិការរង និងទីប្រឹក្សាជាជំនួយការ ។ អគ្គលេខាធិការរង និងទីប្រឹក្សាត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អគ្គលេខាធិការ ដោយមានមតិយល់ព្រមពីប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

មាត្រា ៨ ._

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

មាត្រា ៩ ._

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីបំពេញការងាររបស់ខ្លួន ។

## ជំពូកទី ៤

## ប្រភពធនធាន

មាត្រា ១០ ._

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ១១ ._

ធនធាន និងថវិការបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានផ្តល់ផ្គង់ដោយ :

-វិភាគទាន នៃថវិកាជាតិ

-ហិរញ្ញប្បទានបានមកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា ១២ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣ ._

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ស្ថាប័ន និងសមាជិកទាំងអស់ នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

សមាជិកអចិន្ត្រៃយ៍

ហត្ថលេខា

សុខ អាន

★★★

## អនុក្រឹត្យលេខ ៨៩ អនក្រ.បក

## ស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-** ត្រូវបានបង្កើត ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច សំរាប់ជំនួយការ ក្នុងកិច្ចប្រតិបត្តិការបេសកកម្មរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងវិស័យអភិវឌ្ឍន៍សង្គមកិច្ច ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចមានទីតាំងស្ថិតនៅ ទីស្តីការក្រសួងផែនការ ។

## ជំពូកទី ២

## បេសកកម្ម និង សមាសភាព

**មាត្រា ២ .-** ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានបេសកកម្ម ផ្តួចផ្តើម ជំរុញ ដាក់អោយដំណើរការ សំរបសំរួល និងតាមដានការអនុវត្តន៍នយោបាយ និងកម្មវិធីអភិវឌ្ឍន៍សង្គមកិច្ច ស្របតាមការតំរង់ទិសរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៣ .-** ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានមុខងារ និងភារកិច្ចដូចៈ

១-ផ្តួចផ្តើម និងលើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែ[illegible] ទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីនានា សំរាប់ធ្វើអោយសំរេច នូវ[illegible] ារកាត់បន្ថយភាពក្រីក្រដោយផ្តោតការអភិវឌ្ឍន៍ទៅលើវិស័យ អប់រំ សុខាភិបាល សង្គមកិ[illegible] សិកម្ម និង អភិវឌ្ឍន៍ជនបទ ។

២-អនុវត្តសេចក្តីណែនាំនានារបស់ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការដាក់អោយដំណើរការនូវយុទ្ធសាស្ត្រ និងកម្មវិធីសំរាប់អភិវឌ្ឍន៍សង្គមកិច្ច ។

៣-ចេញសេចក្តីសំរេច និងសេចក្តីណែនាំចាំបាច់ ដល់គ្រប់ក្រសួងស្ថាប័ន ដើម្បីដាក់អោយដំណើរការនូវកម្មវិធីអភិវឌ្ឍន៍សង្គមកិច្ច ក្នុងព្រំដែនសមត្ថកិច្ចរបស់ខ្លួន ។

៤-ជំរុញ និងសំរបសំរួល បណ្តាសកម្មភាពរបស់ក្រសួងស្ថាប័ន ដែលទាក់ទងទៅនឹងកម្មវិធីសំរាប់អភិវឌ្ឍន៍សង្គមកិច្ច ។

៥-តាមដានការអនុវត្តន៍ កម្មវិធីអភិវឌ្ឍន៍សង្គមកិច្ច នៅតាមក្រសួងស្ថាប័នរដ្ឋ និងរាយការណ៍ពីលទ្ធផលទទួលបាន ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

៦-លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគំរោងច្បាប់ លិខិតបទដ្ឋាន និងវិធានការចាំបាច់ ក្នុងការដាក់អោយដំណើរការ ការអភិវឌ្ឍន៍សង្គមកិច្ច ។

៧-យកចិត្តទុកដាក់ ធ្វើទំនាក់ទំនង និងសំរបសំរួល ក្នុងការកេណ្ឌធនធានរបស់រដ្ឋ និងជំនួយអន្តរជាតិចាំបាច់ សំរាប់យកមកប្រើប្រាស់ ក្នុងការដាក់អោយដំណើរការ នូវកម្មវិធីអភិឌ្ឍន៍សង្គមកិច្ច ។

៨-ផ្តល់ជូនដល់ក្រសួងស្ថាប័នរដ្ឋ ក្នុងព្រំដែនសមត្ថកិច្ចរបស់ខ្លួន នូវបង្អែកបច្ចេកទេស ដែលមានអត្ថប្រយោជន៍ ដល់ក្រសួងស្ថាប័នទាំងអស់នោះ ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍សង្គមកិច្ច ។

៩-ជំរុញ និងដឹកនាំគ្រប់គ្រងការងារ ផ្សព្វផ្សាយពត៌មាន ស្តីពីគោលដៅ សមត្ថកិច្ច និងសមិទ្ធផលនៃការងារអភិវឌ្ឍន៍សង្គមកិច្ច ។

១០-បំពេញមុខងារ និងភារកិច្ចចាំបាច់ដទៃទៀត ដែលឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋប្រគល់ជូន។

មាត្រា ៤ .- ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១-រដ្ឋមន្ត្រី ក្រសួងផែនការ | ប្រធាន |
| ២-រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-រដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៦-រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ៧-រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨-រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | សមាជិក |
| ៩-រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |
| ១០-រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១-អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អគ្គលេខាធិការ |
| ១២-អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១៣-អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

មាត្រា ៥ ._ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវបំពេញមុខងារទាំងឡាយរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ដូចមានចែងក្នុងមាត្រាខាងលើ និងយកចិត្តទុកដាក់ធ្វើអោយដំណើរការ នៃការអភិវឌ្ឍន៍សង្គមកិច្ចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព

-កំណត់របៀបវារៈនៃកិច្ចប្រជុំនានា របស់ក្រុមក្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច

-ដឹកនាំការពិភាក្សា និងចេញនូវសេចក្ដីសំរេចនានា ។

មាត្រា ៦ ._ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនដែលមានគុណសម្បត្តិគ្រប់គ្រាន់ មកចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ។

មាត្រា ៧ ._ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានសិទ្ធិក្នុងការចុះហត្ថលេខាទ្វេភាគី និងពហុភាគី លើគ្រប់អនុស្សរណៈនៃហិរញ្ញប្បទាន និងគ្រប់កិច្ចសន្យា ឬអត្ថបទគតិយុត្ត ដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍សង្គមកិច្ច ។

មាត្រា ៨ ._ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានសិទ្ធិអំណាចគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង រដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។

មាត្រា ៩ ._ ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍សង្គមកិច្ច មានសិទ្ធិលើកសំណើតែងតាំង តាមករណីចាំបាច់នូវអ្នកជំនាញការជាតិ និងអន្តរជាតិ ហើយនិងឥស្សរជន ឬមន្ត្រីរាជការជាន់ខ្ពស់ ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច ឬអភិបាលកិច្ច ជាទីប្រឹក្សាបច្ចេកទេស ដើម្បីសិក្សាវិភាគធ្វើទស្សនាទាន ឬធ្វើផែនការកម្ម លើវិស័យអភិវឌ្ឍន៍សង្គមកិច្ច ព្រមទាំងលើកសំណើជូនក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច នូវគំរោងរយៈពេលខ្លី មធ្យម និងវែង ។

មាត្រា ១០ ._ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានសិទ្ធិប្រើប្រាស់ត្រារបស់ខ្លួនដំណើរការ ក្នុងកិច្ចដំណើរការរបស់ខ្លួន ។

## ជំពូកទី ៣

## អគ្គលេខាធិការដ្ឋាន

មាត្រា ១១ ._ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ចមាន អគ្គលេខាធិការដ្ឋាន ជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយ អគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។

មាត្រា ១២ ._ អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានអគ្គលេខាធិការរង និងទីប្រឹក្សា ជាជំនួយការ ។ អគ្គលេខាធិការរង និងសមាជិកក្រុមប្រឹក្សា ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អគ្គលេខាធិការ ដោយមានការយល់ស្របពី ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ។

មាត្រា ១៣ ._ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

ជំពូកទី ៤

ប្រភពធនធាន

មាត្រា ១៤ ._ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានខ្ទង់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងផែនការ ។

មាត្រា ១៥ ._ ធនធាន និងថវិការបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ត្រូវបានផ្តល់ផ្គង់ដោយថវិកាជាតិ និងហិរញ្ញប្បទានពីបរទេស អង្គការ និងធនាគារអន្តរជាតិ ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា ១៦ ._ អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការតាមដានដំណើរការបែងចែកជំនួយសំរាប់ការងារសង្គមកិច្ច និងបទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧ ._ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

សមាជិកអចិន្ត្រៃយ៍

ហត្ថលេខា

សុខ អាន

★★★

## អនុក្រឹត្យលេខ ៩០ អនក្រ.បក

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.៧៥០ លានរៀល ( មួយពាន់ប្រាំពីររយហាសិបលានរៀល ) ពីជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់តូច ) របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ។

**មាត្រា ២ .-** ឥណទានថវិកាក្នុងមាត្រា ១ ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ទូទាត់ឯកសណ្ឋានឆ្នាំ ២០០០ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## អនុក្រឹត្យលេខ ៩១ អនក្រ.បក
## ស្តីពីការផ្ទេរឥណទានថវិកា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ ._** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាសរុប ចំនួន ៣៤៧ លានរៀល (បីរយសែសិបប្រាំពីរលានរៀល) ពីជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) ចំនួន ២៦៤ លានរៀល (ពីររយហុកសិបបួនលានរៀល) និង ពីជំពូក ៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា) ចំនួន ៨៣ លានរៀល (ប៉ែតសិបបីលានរៀល) មកជំពូក ១០(បៀវត្ស និងប្រាក់បំណាច់), ចំនួន ១២០ លានរៀល (មួយរយម្ភៃលានរៀល) និងជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់តូច) ចំនួន ២២៧ លានរៀល (ពីររយម្ភៃប្រាំពីរលានរៀល) របស់ក្រសួងអប់រំយុវជន និងកីឡា ផ្នែក អប់រំ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ។

**មាត្រា ២ ._** ឥណទានថវិកាក្នុងមាត្រា ១ ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ បៀវត្សមូលដ្ឋានប្រចាំឆ្នាំ ប្រាក់រង្វាន់គរុកោសល្យ នឹង ក្រដាសបោះពុម្ព និង សំភារៈការិយាល័យ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំយុវជន និងកីឡាត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

**អនុក្រឹត្យលេខ ៩២ អនក្រ.បក**

**ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមលើឥណទានថវិកា**

**របស់ទីស្តីការ គណៈរដ្ឋមន្ត្រីសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស្ម/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០

- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ .- ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ៥៤.០០០ លានរៀល ( ហាសិបបួនពាន់លានរៀលគត់ ) ទៅលើសៀវភៅថវិកា របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ។

មាត្រា ២ .- ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើ ត្រូវបានផ្តល់បន្ថែមនៅ ជំពូក ១១ (ចំណាយពំពេញការរដ្ឋបាល សំភារៈ និងការជួសជុលតូចៗ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ចំណាយពិសេសរបស់នាយករដ្ឋមន្ត្រី (ចំណាយសង្គ្រោះប្រជាជនដែលរងគ្រោះដោយទឹកជំនន់) ។

មាត្រា ៣ .- ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៤ .- ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខ កាលបើចំណាយពិសេសនេះត្រូវបានចប់សព្វគ្រប់ ។

មាត្រា ៥ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

★★★

**អនុក្រឹត្យលេខ ៩៣ អនក្រ.បក**

**ស្តីពីការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ ._** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ពីជំពូក ៤០ (ចំណាយផ្សេងៗ) ចំនួន ៣.០០០ លានរៀល (បីពាន់លានរៀលគត់) និង ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក) ចំនួន ៤.០០០ លានរៀល (បួនពាន់លានរៀលគត់) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ចំនួន ៦.១៩៤ លានរៀល (ប្រាំមួយពាន់មួយរយកៅសិបបួនលានរៀលគត់) មកជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) ចំនួន ៦១០ លានរៀល (ប្រាំមួយរយដប់លានរៀលគត់) មកជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) ចំនួន ១៨៥ លានរៀល (មួយរយប៉ែតសិបប្រាំលានរៀល) និងមកជំពូក ៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា) ចំនួន ១១ លានរៀល (ដប់មួយលានរៀលគត់) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ។

**:: ២ ._** ឥណទានថវិកាក្នុងមាត្រា ១ ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ទូទាត់ចំណាយជាប្រចាំ ឆ្នាំ ២០០០ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៩៤ អនក្រ.បក

## ស្តីពីការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- យោងតាមតំរូវការចាំបាច់នៃការងារ

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១ ._

បង្កើត " វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា " ជាវិទ្យាស្ថានឯកជនមិនស្វែងរកចំណេញ ដែលរាជរដ្ឋាភិបាលទទួលស្គាល់នូវសកម្មភាពទាំងឡាយ ក្នុងគោលបំណងផ្តល់

សេវាបំរើប្រយោជន៍សាធារណៈក្នុងទិសដៅដើម្បីលើកកំពស់ការអភិវឌ្ឍន៍ធនធានមនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើការស្រាវជ្រាវវិភាគ និង ដើម្បីរួមចំណែកដល់ការកសាងគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ អោយមានចីរភាព ។

មាត្រា ២ ._

១-វិទ្យាស្ថាននេះមានគោលដៅដូចតទៅ :

. លើកកំពស់សមត្ថភាពរបស់ប្រជារាស្ត្រ និងស្ថាប័នកម្ពុជា ក្នុងការគ្រប់គ្រងដំណើរការអភិវឌ្ឍន៍

. ផ្តល់លទ្ធភាពដល់ប្រជារាស្ត្រកម្ពុជា ក្នុងការចូលរួមអោយបានពេញលេញ និងមានសមត្ថភាព នៅក្នុងការកំណត់អាទិភាព និងគោលដៅនានា សំរាប់ការអភិវឌ្ឍន៍

. រួមចំណែកដល់ការកសាងគោលនយោបាយអភិវឌ្ឍន៍មានចីរភាព ដែលស្របតាមបំណងប្រាថ្នា របស់ប្រជារាស្ត្រកម្ពុជា តាមរយៈការស្រាវជ្រាវខាងសេដ្ឋកិច្ច សង្គមកិច្ច

. ផ្តល់វេទិកាសំរាប់ពិភាក្សាលើបញ្ហាចោទ និងដំណោះស្រាយផ្សេងៗ ស្តីពីការអភិវឌ្ឍន៍

. ជំរុញការយល់ដឹង ដោយមានពត៌មានច្បាស់លាស់ពីប្រទេសកម្ពុជា និងអំពីបទពិសោធន៍ក្នុង ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា នៅក្នុងចំណោមសហគមន៍អន្តរជាតិ ។

២- វិទ្យាស្ថានបំពេញសកម្មភាពរបស់ខ្លួន ដោយមិនយកផលចំណេញជាប្រាក់កាសដល់សមាជិករបស់ខ្លួនទេហើយប្រាក់ចំណេញ ឬវិភាគទានផ្សេងៗ ដែលវិទ្យាស្ថានរកបាន នឹងត្រូវប្រើប្រាស់សំរាប់បំរើគោលដៅរបស់វិទ្យាស្ថាន ។

៣- វិទ្យាស្ថានត្រូវដំណើរការ ដោយធ្វើជាដៃគូជាមួយបណ្តាស្ថាប័នសាធារណៈ និងអង្គការសង្គមស៊ីវិលទាំងនៅក្នុងប្រទេសកម្ពុជា និងនៅអន្តរជាតិ ។

## ជំពូកទី ២
## បុគ្គលិកលក្ខណៈគតិយុត្ត និងការគ្រប់គ្រង

មាត្រា ៣ ._

-វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ជានីតិបុគ្គលដែលមានស្វ័យភាពក្នុងការ គ្រប់គ្រងទាំងផ្នែករដ្ឋបាល និងទាំងខាងហិរញ្ញវត្ថុ ។

-វិទ្យាស្ថានត្រូវបានបង្កើត និងដំណើរការ នៅក្រោមច្បាប់គ្រប់គ្រងស្ថាប័នឯកជនមិនស្វែងរកចំណេញ ដើម្បីផ្តល់សេវាសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤ ._

វិទ្យាស្ថានត្រូវមានទីស្នាក់ការកណ្តាលស្ថិតនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ វិទ្យាស្ថានអាចផ្លាស់ប្តូរទីស្នាក់ការ អាចបង្កើតការិយាល័យ និងទីភ្នាក់ងារ ឬសាខារបស់ខ្លួន នៅទីកន្លែងនានានៅ ក្នុង ឬនៅក្រៅប្រទេសកម្ពុជាទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ៥ ._

វិទ្យាស្ថានត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលត្រូវរៀបរៀងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន តាមការសំរេចភាគច្រើនរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ៦ ._

១-សមាជិកភាពនៅក្នុងក្រុមប្រឹក្សាភិបាល ត្រូវបានផ្តល់ទៅអោយតែរូបវន្តបុគ្គលណាដែលមានគោលបំណងនិងមានទិសដៅដូចគ្នានឹងវិទ្យាស្ថាន ។

២-សមាជិកណាម្នាក់អាចលាឈប់ពីក្រុមប្រឹក្សាភិបាលបាន តាមការប្រគល់ជូនសហប្រធានក្រុមប្រឹក្សាភិបាលនូវលិខិតសុំលាឈប់ជាលាយលក្ខអក្សរមួយច្បាប់ ។

៣-សមាជិកណាម្នាក់អាចត្រូវបានតំរូវអោយលាឈប់ពីតំណែងនេះ តាមការបោះឆ្នោតមួយដែលមានការអនុម័តយ៉ាងតិចពីរភាគបីនៃសមាជិកដែលមានវត្តមាននៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែអង្គប្រជុំត្រូវតែផ្តល់ឱកាសជូនដល់សាមីខ្លួន បកស្រាយពីហេតុការណ៍ជូនអង្គប្រជុំផង ។

៤-ទ្រព្យសម្បត្តិ និងការងាររបស់វិទ្យាស្ថាន ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាជិកមិនតិចជាង ៩ នាក់ និងមិនច្រើនជាង ១៥ នាក់ ។ អង្គប្រជុំណាមួយនៃក្រុមប្រឹក្សាភិបាលដែលមានវត្តមានសមាជិកលើសពាក់កណ្តាលនៃចំនួនសមាជិកសរុប ត្រូវបានចាត់ទុកថា មានកូរ៉ុមគ្រប់គ្រាន់ ។

មាត្រា ៧ ._

១-ក្រុមប្រឹក្សាភិបាលមានតួនាទី និងភារកិច្ចដូចតទៅ ៖

- កំណត់បេសកកម្ម និងគោលដៅរបស់វិទ្យាស្ថាន
- ជ្រើសរើស ជួយទ្រទ្រង់ និងត្រួតពិនិត្យលទ្ធផលការងាររបស់នាយកប្រតិបត្តិ
- ធានាអោយមានការធ្វើផែនការជាក់ស្តែង
- ធានាអោយមានធនធានហិរញ្ញវត្ថុ និងការគ្រប់គ្រងសមស្រប
- តាមដានកម្មវិធី និងសេវា ធ្វើការពិនិត្យតាមដានពីគុណភាពនៃកម្មវិធីសិក្សា
- ធានាអោយមានវេទិកាមួយសំរាប់ដោះស្រាយវិវាទ
- ជួយលើកស្ទួយកេរ្តិ៍ឈ្មោះវិទ្យាស្ថាន ។

២-ក្រុមប្រឹក្សាភិបាលអាណត្តិទី១ ជាអ្នកចុះហត្ថលេខាលើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន ។

៣-តាមការចាំបាច់ ក្រុមប្រឹក្សាភិបាលអាចកំណត់ចេញនូវវិធាន និងបទប្បញ្ញត្តិនានាដែលមិនផ្ទុយនឹងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង ហើយដែលជាប់ពាក់ព័ន្ធដល់ការគ្រប់គ្រង និងប្រតិបត្តិការរបស់វិទ្យាស្ថាន ។

៤-សមាជិកក្រុមប្រឹក្សាភិបាលត្រូវធានាថា រាល់សៀវភៅ បញ្ជី និងកំណត់ត្រា ដ៏ចាំបាច់នានា ដែលលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ឬច្បាប់ បានតម្រូវ ត្រូវបានកាន់កាប់ កត់ត្រាយ៉ាងទៀងទាត់ និងត្រឹមត្រូវ ។

៥-ក្រុមប្រឹក្សាភិបាលត្រូវជ្រើសតាំងសមាជិកគណៈកម្មាធិការប្រតិបត្តិ នាយកប្រតិបត្តិ និងនាយករងរបស់វិទ្យាស្ថាន ។

## មាត្រា ៨ ._

ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិក ៥០% ជាបុគ្គលិកមានដើមកំណើតជាខ្មែរ និង ៥០ % ទៀតជាសមាជិកបរទេស ។ ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចតទៅ :

- នាយកប្រតិបត្តិនៃវិទ្យាស្ថាន
- តំណាងមួយរូបនៃបុគ្គលិករបស់វិទ្យាស្ថាន ។ តំណាងនេះត្រូវបានបោះឆ្នោតជ្រើសរើសប្រចាំឆ្នាំ ដោយបុគ្គលិកមានសិទ្ធិរបស់វិទ្យាស្ថាន
- នាយករង ក្នុងឋានៈជាសមាជិកគ្មានសិទ្ធិបោះឆ្នោត ។

## មាត្រា ៩ ._

-សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល សំរាប់អាណត្តិមួយមានរយៈ ពេល ៣ ឆ្នាំ ។ សមាជិកក្រុមប្រឹក្សាភិបាល អាចត្រូវបានជ្រើសតាំងសំរាប់មួយអាណត្តិថែមទៀតបាន ។

-នៅក្នុងពេលបំរើការ សមាជិកក្រុមប្រឹក្សាភិបាល មិនត្រូវបានផ្តល់នូវលាភការអ្វីឡើយ ។ ប៉ុន្តែសមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានទូទាត់សងវិញនូវចំណាយនានារបស់ខ្លួនក្នុងការមកចូលរួមប្រជុំប្រចាំឆ្នាំ ឬការប្រជុំជាពិសេសផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល ។

## មាត្រា ១០ ._

ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការប្រជុំដូចបានកំណត់ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ។

១-ក្រុមប្រឹក្សាភិបាល ត្រូវជួបប្រជុំប្រចាំឆ្នាំ ដើម្បីទទួលរបាយការណ៍របស់សមាជិកគណៈកម្មាធិការប្រតិបត្តិរបាយការណ៍គណនេយ្យ របាយការណ៍របស់សវនករវិទ្យាស្ថាន និងដើម្បីជ្រើសតាំងសវនករសំរាប់ឆ្នាំបន្ទាប់ទៀត ។

២-ការប្រជុំប្រចាំឆ្នាំ ត្រូវធ្វើឡើងនៅទីស្នាក់ការរបស់វិទ្យាស្ថាន ឬនៅកន្លែងណាមួយផ្សេងទៀតតាមការកំណត់ និងតាមកាលបរិច្ឆេទរបស់ក្រុមប្រឹក្សាភិបាល ។

៣-ក្រុមប្រឹក្សាភិបាល អាចកោះប្រជុំជាពិសេសនៅគ្រប់ពេល តាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ឬតាមសំណើជាលាយលក្ខអក្សររបស់សមាជិកក្រុមប្រឹក្សាយ៉ាងតិច ៥០%។

៤-ក្រុមប្រឹក្សាភិបាល ត្រូវខិតខំស្វែងរកកុងសង់ស៊ុសសំរាប់រាល់សេចក្តីសំរេចរបស់ខ្លួន ប៉ុន្តែក្នុងករណីពុំមានកុងសង់ស៊ុស សេចក្តីសំរេចត្រូវធ្វើឡើងតាមសំលេងភាគច្រើនដាច់ខាតនៃ

សមាជិកក្រុមប្រឹក្សាភិបាលដែលមានវត្តមាននៅក្នុងការប្រជុំ និងដែលមានសិទ្ធិបោះឆ្នោតដូចមានចែងនៅក្នុងផ្នែកនេះ ។

មាត្រា ១១ ._

ក្រុមប្រឹក្សាភិបាល មានសិទ្ធិបង្កើតគណៈកម្មាធិការប្រតិបត្តិតាមការចាំបាច់ ។

១-សមាសភាពគណៈកម្មាធិការប្រតិបត្តិរួមមាន ៈ ប្រធានកិត្តិយសមួយរូប សហប្រធានពីររូបលេខាធិការមួយរូប និងហិរញ្ញិកមួយរូប ដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល ។ តួនាទីជា លេខាធិការ និងនាយកប្រតិបត្តិ អាចកាន់កាប់ដោយសមាជិកតែមួយរូបបាន ។

២-នៅចន្លោះពេលពីការប្រជុំមួយទៅការប្រជុំមួយទៀតរបស់ក្រុមប្រឹក្សាភិបាល សមាជិកនៃ**គណៈកម្មាធិការប្រតិបត្តិ ត្រូវចាត់ចែងរាល់កិច្ចការរបស់វិទ្យាស្ថាន ទៅតាមតំរូវការនៃការងារ ។ នៅក្រៅពេលដែលក្រុមប្រឹក្សាភិបាលជួបប្រជុំគ្នា គណៈកម្មាធិការប្រតិបត្តិមានសិទ្ធិអំណាចពេញលេញ ក្នុងការអនុវត្តន៍សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាភិបាល លើកលែងតែសិទ្ធិអំណាចក្នុងការ ១. ធ្វើវិសោធនកម្ម អនុម័ត ឬលុបចោលលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ**ក្នុងរបស់វិទ្យាស្ថាន ២. បំពេញអាសនៈទំនេរនៅក្នុងគណៈកម្មាធិការប្រតិបត្តិ ៣.ធ្វើវិសោធនកម្ម ឬលុបចោលសេចក្តីសំរេចណាមួយរបស់ក្រុមប្រឹក្សាភិបាល និង ៤. ធ្វើវិសោធនកម្ម ឬលុបចោលកំហិតណាមួយ ដែលក្រុមប្រឹក្សាភិបាលបានចេញសេចក្តីសំរេចដាក់មកលើគណៈកម្មាធិការប្រតិបត្តិ ។ រាល់សកម្មភាពរបស់គណៈកម្មាធិការប្រតិបត្តិ ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលនៅក្នុងការប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាភិបាល ។

៣-គណៈកម្មាធិការប្រតិបត្តិត្រូវជួបប្រជុំតាមពេលវេលាកំណត់ច្បាស់លាស់ ឬតាមការជូនដំណឹងដល់សមាជិកទាំងអស់ តាមសំណើរបស់សហប្រធានម្នាក់ ឬទាំងពីរនាក់ ឬរបស់លេខាធិការ ។

៤-គណៈកម្មាធិការប្រតិបត្តិត្រូវកំណត់នីតិវិធីដើម្បីអនុវត្តការងាររបស់ខ្លួន ។ ការប្រជុំណាមួយរបស់គណៈកម្មាធិការប្រតិបត្តិដែលមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃចំនួនសមាជិកសរុប ត្រូវបានចាត់ទុកថា មានកូរ៉ុមគ្រប់គ្រាន់ ។ គណៈកម្មាធិការប្រតិបត្តិអាចសំរេចលើករណីណាមួយបាន លុះត្រាតែមានការបោះឆ្នោតគាំទ្រដោយសម្លេងភាគីច្រើនដាច់ខាតនៃសមាជិក ។

មាត្រា ១២ ._

គណៈកម្មាធិការប្រតិបត្តិមានភារកិច្ចដូចតទៅ ៈ

១-សមាជិកគណៈកម្មាធិការប្រតិបត្តិ ត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិមួយដែលមានរយៈពេលមួយឆ្នាំ ដោយក្រុមប្រឹក្សាភិបាលនៅក្នុងការប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល ។

អាណត្តិរបស់សមាជិកគណៈកម្មាធិការប្រតិបត្តិ ត្រូវចាប់ផ្តើមនៅពេលបិទការប្រជុំដែលមានការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការប្រតិបត្តិនោះ និងត្រូវចប់នៅពេលបិទការប្រជុំដែលមានការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការប្រតិបត្តិដែលត្រូវមកទទួលតំណែងបន្ត ។ នៅគ្រប់ពេលក្រុមប្រឹក្សាភិបាលអាចចេញសេចក្តីសំរេចដកហូតតួនាទីជាសមាជិកគណៈកម្មាធិការប្រតិបត្តិរបស់បុគ្គលណាម្នាក់នៅក្នុងគណៈកម្មាធិការប្រតិបត្តិបាន ។

២-ប្រធានកិត្តិយស ត្រូវបានតែងតាំងឡើងដោយក្រុមប្រឹក្សាភិបាល ។ ប្រធានកិត្តិយស ត្រូវតែជាបុគ្គលមួយរូបដែលសហគមន៍កម្ពុជា និងអន្តរជាតិ មានការគោរពរាប់អានជាទីបំផុត ។ ប្រធានកិត្តិយសត្រូវតំណាងអោយវិទ្យាស្ថាននៅចំពោះមុខរដ្ឋាភិបាល និងមជ្ឈដ្ឋាននានាដែលពាក់ព័ន្ធនឹងវិទ្យាស្ថាន ។

៣-សហប្រធានទាំងពីរ បើសិនមានវត្តមាន ត្រូវធ្វើជាប្រធានសំរាប់រាល់ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការប្រតិបត្តិ ។ សហប្រធានទាំងពីរត្រូវទទួលបន្ទុកតាមដានពិនិត្យរាល់កិច្ចការ និងប្រតិបត្តិការជាទូទៅរបស់វិទ្យាស្ថាន ។ ក្នុងករណីមានសហប្រធានមួយរូបអវត្តមាន ឬអសមត្ថភាពសហប្រធានមួយរូបទៀតត្រូវបំពេញភារកិច្ច និង អនុវត្តសិទ្ធិអំណាចរបស់ប្រធាន ហើយត្រូវបំពេញភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាភិបាលបានកំណត់ ។ បើសិនជា សហប្រធានទាំងពីរមិនអាចបំពេញភារកិច្ចក្នុងតួនាទីរបស់ខ្លួនបាន ទេ ក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលមួយរូបអោយអនុវត្តភារកិច្ច របស់ប្រធានសំរាប់រយៈពេលមួយតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-លេខាធិការត្រូវធានាថា រាល់ការបោះឆ្នោតរបស់សមាជិកក្រុមប្រឹក្សាភិបាល រាល់កំណត់ហេតុនៃការប្រជុំនានារបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ ត្រូវកត់ត្រានៅក្នុងសៀវភៅមួយ ឬ ច្រើនដែលត្រូវបានរក្សាទុកសំរាប់គោលដៅនេះ ។ លេខាធិការត្រូវធានាថារាល់លិខិតសំរាប់ជូនដំណឹងស្តីពីការប្រជុំនៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិត្រូវបានប្រគល់អោយអ្នកដែលត្រូវទទួល ហើយរាល់កំណត់ត្រា និងរបាយការណ៍ត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវតាមការតំរូវនៃច្បាប់ ។ ជារួមលេខាធិការត្រូវបំពេញភារកិច្ចដែលផ្សារភ្ជាប់នឹងតួនាទីជាលេខាធិការ និងភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាភិបាល ឬសហប្រធានបានកំណត់ ។

៥-ហិរញ្ញិកត្រូវថែរក្សាមូលនិធិ មូលប័ត្ររបស់វិទ្យាស្ថាន ហើយត្រូវធានាថា កំណត់ត្រាពេញលេញ និងលំអិត នៃចំណូលចំណាយ ត្រូវបានរក្សាទុកនៅក្នុងបញ្ជីរបស់វិទ្យាស្ថាន និងនៅតាមកន្លែងទុកដាក់ផ្សេងទៀតតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល ។ ហិរញ្ញិកត្រូវបញ្ចេញមូលនិធិរបស់វិទ្យាស្ថានតាមការបញ្ជារបស់ក្រុមប្រឹក្សាភិបាល ដោយមានសក្ខីប័ត្រសមស្របបញ្ជាក់នូវការបើកប្រាក់ទាំងនេះ ហើយត្រូវផ្តល់ជូនសហប្រធាន និងក្រុមប្រឹក្សាភិបាលនៅពេល

ប្រជុំប្រចាំឆ្នាំ និងនៅគ្រប់ពេលដែលសហប្រធាន ឬក្រុមប្រឹក្សាភិបាលបានតំរូវឡើង នូវរបាយការណ៍ស្តីពីប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ដែលខ្លួនបានធ្វើក្នុងតួនាទីជាហិរញ្ញិក និងរបាយការណ៍ពីស្ថានភាពហិរញ្ញវត្ថុរបស់វិទ្យាស្ថាន ។ ហិរញ្ញិកត្រូវបំពេញផងដែរនូវភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាភិបាលបានកំណត់ ។

មាត្រា ១៣ ._

ក្រុមប្រឹក្សាភិបាលអាចបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការពិសេសៗ ដែលមានសមាជិកមួយ រូប ឬច្រើនរូប ដោយក្នុងនេះ សមាជិកមួយរូប គឺជាសមាជិកក្រុមប្រឹក្សាភិបាលដែលត្រូវបានសហប្រធានតែងតាំងឡើង ។ គណៈកម្មាធិការទាំងនេះ ត្រូវបំពេញភារកិច្ច ធ្វើការស៊ើបអង្កេត និងធ្វើរបាយការណ៍ផ្សេងៗ ទៅតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុរបស់វិទ្យាស្ថាន

មាត្រា ១៤ ._

១-វិទ្យាស្ថានត្រូវកាន់កាប់កំណត់ត្រានានាអោយបានត្រឹមត្រូវ ហើយត្រូវឆ្លុះបញ្ចាំងអោយឃើញនូវ :

- ចំណូល និងចំណាយលំអិតរបស់វិទ្យាស្ថាន
- ទ្រព្យសកម្មនានាដែលវិទ្យាស្ថានកាន់កាប់
- ទ្រព្យអកម្មនានារបស់វិទ្យាស្ថាន ។

២-រៀងរាល់ឆ្នាំ បញ្ជីគណនេយ្យរបស់វិទ្យាស្ថានត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យមួយរូបដែលត្រូវបានជ្រើសតាំងឡើងស្របតាមមាត្រា ១៣ នៃជំពូកនេះ ។

៣-ការិយបរិច្ឆេទត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែ មករា និងត្រូវបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ក្នុងឆ្នាំដដែល ។

៤-នៅចុងការិយបរិច្ឆេទនីមួយៗ ត្រូវធ្វើបញ្ជីចំណូលចំណាយ តារាងតុល្យការ និងត្រូវផ្ញើច្បាប់ចំលងនៃឯកសារទាំងនេះទៅអោយគ្រប់សមាជិកក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន ។ បញ្ជីចំណូលចំណាយតារាងតុល្យការ ត្រូវបានធ្វើឡើងស្របតាមស្តង់ដាគណនេយ្យជាធរមាន និងត្រូវភ្ជាប់របាយការណ៍មួយរបស់សវនករដែលបញ្ជាក់ថា គណនីនានាបានឆ្លុះបញ្ចាំងអំពីលក្ខណៈត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនៅលើកិច្ចការរបស់វិទ្យាស្ថាន ហើយទ្រព្យសកម្មនានាត្រូវបានត្រួតពិនិត្យ និងតំលៃនានាត្រូវបានកំណត់ត្រឹមត្រូវ ។

មាត្រា ១៥ ._

នៅរាល់ការប្រជុំទៀងទាត់របស់ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាភិបាលត្រូវជ្រើសតាំងសវនករឯករាជ្យមួយរូបដើម្បីធ្វើសវនកម្មលើបញ្ជីគណនេយ្យរបស់វិទ្យាស្ថាន ។ សវនករអាចបំពេញតួនាទីនេះ

រហូតដល់ការប្រជុំឆ្នាំបន្ទាប់របស់ក្រុមប្រឹក្សាភិបាល ហើយអាចត្រូវបានជ្រើសតាំងសាជាថ្មីជាបន្តបន្ទាប់ ។ បើសិនជាតួនាទីសវនករនៅទំនេរ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការជ្រើសតាំងបំពេញតួនាទីនេះ ។ លាភការរបស់សវនករ ត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ៤

## ទ្រព្យសម្បត្តិ និង ទ្រព្យសកម្ម របស់វិទ្យាស្ថាន

**មាត្រា ១៦ .-**

អចលនទ្រព្យរបស់វិទ្យាស្ថាន គឺជាទ្រព្យសម្បត្តិឯកជនរបស់វិទ្យាស្ថានដែលត្រូវបានធ្វើលទ្ធកម្ម និងគ្រប់គ្រងទៅតាមវិធាន និងបទប្បញ្ញត្តិរបស់វិទ្យាស្ថាន ឬទៅតាមការកំណត់របស់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ។

ក្នុងករណីដែលវិទ្យាស្ថានត្រូវបានរំលាយតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល អចលនទ្រព្យដំបូងរបស់វិទ្យាស្ថាន ដែលត្រូវបានរាជរដ្ឋាភិបាលផ្តល់អោយ គឺកម្មសិទ្ធិនៅលើទ្រព្យ .... ស្ថិតនៅលេខ ៥៦ ផ្លូវលេខ ៣១៥ ខណ្ឌទួលគោករាជធានីភ្នំពេញ ដែលមានប័ណ្ណកម្មសិទ្ធិលេខ .......... ហើយ ដែលកម្មសិទ្ធិនេះមិនអាចលក់ ផ្ទេរ ដូរ ទៅអោយឯកត្តបុគ្គល ឬ និតិបុគ្គលណាក្រៅពីស្ថាប័នគ្រប់គ្រង សម្បត្តិរដ្ឋរបស់រាជរដ្ឋាភិបាលឡើយ ។

**មាត្រា ១៧ .-**

ចលនទ្រព្យរបស់វិទ្យាស្ថាន គឺជាទ្រព្យសម្បត្តិឯកជនរបស់វិទ្យាស្ថាន ដែលត្រូវបានធ្វើលទ្ធកម្ម និងគ្រប់គ្រងទៅតាមវិធាន និងបទប្បញ្ញត្តិរបស់វិទ្យាស្ថាន ។ ក្នុងករណីដែលវិទ្យាស្ថានត្រូវបានរំលាយតាម សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ចលនទ្រព្យនៅសេសសល់ទាំងអស់របស់វិទ្យាស្ថាន ត្រូវបានផ្ទេរទៅអោយស្ថាប័នដែលមិនស្វែងរកចំណេញនានាទៅតាមការកំណត់របស់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ឬ ទៅតាមការសំរេចជាឯកច្ឆ័ន្ទរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៨ .-**

វិទ្យាស្ថានអាចធ្វើលទ្ធកម្មទ្រព្យសកម្មផ្សេងៗតាមមធ្យោបាយដូចតទៅ ៖

- ប្រាក់កាស ឬទ្រព្យសម្បត្តិដែលទាយកផ្តល់អោយតាមរយៈសំបុត្របណ្តាំ ឬឯកសារផ្លូវការផ្សេងទៀតដោយគ្មានលក្ខខណ្ឌដែលចងវិទ្យាស្ថាន អោយទទួលខុសត្រូវចំពោះបំណុលឬកាតព្វកិច្ចផ្សេងទៀត
- ប្រាក់កាស ឬទ្រព្យសម្បត្តិ ដែលទាយកផ្តល់អោយ
- ការប្រាក់ ឬប្រាក់ចំណូល ដែលបានមកពីទ្រព្យសកម្មរបស់វិទ្យាស្ថាន ។
- ប្រាក់ចំណូលដែលបានមកពីការលក់លទ្ធផលនៃការស្រាវជ្រាវ ឯកសារបោះពុម្ពផ្សាយ កំរែបណ្តុះបណ្តាលកោសល្យវិច័យ និងសេវាផ្សេងៗ ដើម្បីរក្សាចីរភាពនៃវិទ្យាស្ថាន ។

## ជំពូកទី ៥
## វិសោធនកម្ម និង ការរំលាយ

មាត្រា ១៩ ._

លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន ត្រូវបានអនុម័ត និងអាចត្រូវបានធ្វើវិសោធនកម្ម ឬលុបចោលតាមសំលេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងការប្រជុំណាមួយដែលត្រូវបានកោះប្រជុំតាមការជូនដំណឹងដល់សមាជិកក្រុមប្រឹក្សាភិបាលអំពីបំណងនេះ ។ បើសិនក្រុមប្រឹក្សាភិបាលយល់ឃើញថាករណីណាមួយមានលក្ខណៈបន្ទាន់ វិសោធនកម្មអាចអនុម័តយកបានដោយសំលេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាភិបាលដែលបានបោះឆ្នោតតាមរយៈប្រៃសណីយ៍ ទូរស័ព្ទ ទូរសារ បន្ទាប់ពីបានទទួលការជូនដំណឹងអំពីបំណងនេះ ។

មាត្រា ២០ ._

ក្រៅពីការបញ្ចប់សកម្មភាពវិទ្យាស្ថានតាមបទប្បញ្ញត្តិច្បាប់ វិទ្យាស្ថានអាចត្រូវបានរំលាយ បើសិនជាវិទ្យាស្ថានមិនអាចធ្វើប្រតិបត្តិការរបស់ខ្លួនបានដោយប្រការណាមួយ ។ ការរំលាយនេះត្រូវអនុវត្តឡើងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានជាធរមាននៅពេលរំលាយ ។

មាត្រា ២១ ._

វិទ្យាស្ថាន ត្រូវបានគ្រប់គ្រងដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលត្រូវតែរៀបរៀងឡើងអោយស្របតាមវិធាន និងបទប្បញ្ញត្តិនានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

មាត្រា ២២ ._

នៅពេលមានច្បាប់ស្តីពី ការគ្រប់គ្រងស្ថាប័នឯកជនមិនស្វែងរកចំណេញ និងច្បាប់ស្តីពី ការគ្រប់គ្រងសមាគមក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ត្រូវធ្វើការកែសំរួលបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងកែសំរួលលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង អោយបានសមស្របតាមលក្ខខណ្ឌនៃច្បាប់ខាងលើ ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

មាត្រា ២២ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៣ ._

រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ២៨ ._

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៩៥ អនក្រ.បក**

**ស្តីពីការកែសំរួលរចនាសម្ព័ន្ធសមាសភាព និង តួនាទីភារកិច្ច**

**របស់ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ**

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការកែសំរួលរចនាសម្ព័ន្ធសមាសភាពនិង តួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- យោងតាមសំណូមពរចាំបាច់

**សំរេច**

**ជំពូកទី ១**

**អំពីរចនាសម្ព័ន្ធ និង សមាសភាពនៃក្រុមប្រឹក្សា**

**ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ហៅកាត់ថា**

**" កកជ ឬ CARD "**

មាត្រា ១ ._ សមាសភាពក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវបានកែសំរួលដូចតទៅ :

| | |
|---|---|
| -នាយករដ្ឋមន្ត្រី | ប្រធាន |
| -ឥស្សរជនមួយរូបមានឋានៈស្មើរដ្ឋមន្ត្រី | អនុប្រធាន |
| -អនុប្រធានទី ១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |

-រដ្ឋមន្ត្រី ឬ តំណាងទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងមហាផ្ទៃ សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងសុខាភិបាល សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងធនធានទឹក និង ឧតុនិយម សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងបរិស្ថាន សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងផែនការ សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ សមាជិក
-រដ្ឋមន្ត្រី ឬ តំណាងក្រសួងកិច្ចការនារី និង អតីតយុទ្ធជន សមាជិក
-អគ្គទេសាភិបាលធនាគារជាតិ ឬ តំណាង សមាជិក
-ប្រធានធនាគារអភិវឌ្ឍន៍ជនបទ សមាជិក
-ប្រធានមូលនិធិកាត់បន្ថយភាពក្រីក្រ សមាជិក
-អគ្គលេខាធិការ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សមាជិក
-អគ្គនាយកមូលនិធិសង្គម សមាជិក

**មាត្រា ២ ._** បង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិង ជនបទ " **ក.ក.ជ** " ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប និង មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អគ្គលេខាធិការដ្ឋាន នៃ កកជ មានផ្នែកជំនាញចំនួន ៦ ដោយមានមន្ត្រីឯកទេសបំរើការ :

-ផ្នែក រដ្ឋបាល និងហិរញ្ញវត្ថុ
-ផ្នែក កសិកម្ម រួមមាន : ចិញ្ចឹមសត្វ សំភារៈ គ្រឿងយន្ត និង ធនធានមនុស្ស ។ល។
-ផ្នែក កៅស៊ូ
-ផ្នែក អភិវឌ្ឍន៍ជនបទ
-ផ្នែក អាជីវកម្មព្រៃឈើ និង ជលផល
-ផ្នែកធនធានទឹក ( បំរើការងារស្រោចស្រព )

**មាត្រា ៣ ._** អគ្គលេខាធិការមានឋានៈស្មើ រដ្ឋលេខាធិការ ។ អគ្គលេខាធិការរងមានឋានៈស្មើអនុរដ្ឋលេខាធិការ ។ ផ្នែកនីមួយៗមានឋានៈស្មើនាយកដ្ឋានហើយដឹកនាំដោយប្រធានមួយរូប ។

មាត្រា ៤ ._ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ( កកជ ) មានគណៈកម្មាធិការប្រតិបត្តិមួយសំរាប់ដឹកនាំការងារប្រចាំថ្ងៃ ។

គណៈកម្មាធិការប្រតិបត្តិនៃ ( កកជ ) រួមមានសមាសភាពដូចតទៅ :

១-ប្រធាន " កកជ "

២-អនុប្រធាន " កកជ "

៣-អគ្គលេខាធិការ " កកជ "

៤-អគ្គលេខាធិការរង " កកជ "

## ជំពូកទី ២

## អំពីតួនាទី និង ភារកិច្ចរបស់ " កកជ ឬ CARD "

មាត្រា ៥ ._ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានតួនាទីជាគណៈបញ្ញាការឯកភាពមួយជំនួយការអោយរាជរដ្ឋាភិបាល ក្នុងវិស័យស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដោយសហការ គ្នាយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង- ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និង ឧតុនិយម ដើម្បីអនុវត្តអោយស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា នឹងមានប្រសិទ្ធភាព ព្រមទាំងមានសិទ្ធិសំរេចអំពីមគោលនយោបាយ សំភារៈទុន និង ការងារផ្សេងៗទៀតដែលជួយអោយ សំរេចរាល់ភារកិច្ច ដែលមានចែងក្នុងមាត្រា ៦ ។

មាត្រា ៦ ._ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចដូចខាងក្រោម :

-ទទួលបន្ទុកតាមដាន និង ផ្តល់យោបល់លើការអនុវត្តន៍នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និង កម្មវិធីជាតិនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា ចំពោះកិច្ចការស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ សំដៅប្រែក្លាយវិស័យកសិកម្មដែលមានទំពាក់ធ្វើដើម្បីផ្គត់ផ្គង់ខ្លួនឯង អោយទៅជាការផលិតដើម្បីនាំចេញ ព្រមទាំងបន្ថយជាជំហានៗនូវគម្លាតឆ្ងាយរវាង ជនបទ និង ទីក្រុង ។

-កំណត់កត្តាគន្លឹះទាំងឡាយដែលបំរើអោយការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

-កំណត់អាទិភាព និង កម្មវិធីនយោបាយក្នុងការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទអោយសមស្របតាមគោលនយោបាយនៃរាជរដ្ឋាភិបាល ។

-ចលនា និង សំរបសំរួលការចូលរួមយ៉ាងកុះករពីប្រជារាស្ត្រ ជាពិសេសក្រុមហ៊ុនឯកជន សហគមន៍ជនបទ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ជាមួយក្រសួង - ស្ថាប័ន ខេត្ត- ក្រុង ដើម្បីបង្កើ នូវភាពងាយស្រួល និង ភាពសហការល្អក្នុងការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដើម្បីធានាផលិតកម្ម និង អាជីវកម្មដោយនិរន្តរភាព និង ធានាសន្តិសុខស្បៀង កាត់បន្ថយភាព ក្រីក្រនៅជនបទ ។

-ពិនិត្យផ្តល់យោបល់ ដោះស្រាយរាល់សំណើដែលបានស្នើសុំពីក្រសួង- ស្ថាប័ន ដែលពាក់ព័ន្ធ ដល់ការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។ រាយការណ៍ និងសុំយោបល់រាជរដ្ឋាភិបាលលើបញ្ហាសំខាន់ៗ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

### ជំពូកទី ៣

### ដំណើរការប្រព្រឹត្តិទៅរបស់ " គកជ ឬ CARD "

មាត្រា ៧ ._ ប្រធាន " គកជ " មានតួនាទី និងភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវលើការងាររបស់ " គកជ "

-ធ្វើជាអធិបតីភាពក្នុងអង្គប្រជុំរបស់ " គកជ " និង អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិការ " គកជ " ។

-ដឹកនាំពិភាក្សា និង បូកសរុបមតិសំរេចរបស់អង្គប្រជុំពេញអង្គ " គកជ " និង អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិរបស់ " គកជ " ។

-កោះប្រជុំសាមញ្ញ ឬ ក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញនៃអង្គប្រជុំ " គកជ " និង អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ " គកជ " ។

មាត្រា ៨ ._ អនុប្រធាន " គកជ " មានតួនាទី និង ភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវជាទូទៅលើការងារ " គកជ " ក្នុងករណីប្រធានអវត្តមាន

-ទទួលខុសត្រូវក្នុងការដឹកនាំ និង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ " គកជ "

-ធ្វើជាអធិបតីនៃអង្គប្រជុំ " គកជ " និង អង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ " គកជ " និងចុះហត្ថលេខាលើកំណត់ហេតុ និង លើសេចក្តីជូនដំណឹងនៃអង្គប្រជុំរបស់ " គកជ " ។

-ទទួលបន្ទុកការងារសំរបសំរួលអន្តរក្រសួងរវាង " គកជ " ជាមួយក្រសួង -ស្ថាប័ននៃរាជរដ្ឋាភិបាល ។

-ទទួលបន្ទុកទំនាក់ទំនងជាមួយភាគីបរទេស ដែលពាក់ព័ន្ធក្នុងការងារស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

មាត្រា ៩ ._ អគ្គលេខាធិការ " គកជ " មានតួនាទី និង ភារកិច្ចដូចតទៅ :

-ទទួលបន្ទុកចាត់ចែងគ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ " គកជ " ។

-រៀបចំកម្មវិធីរបស់ " គកជ " និងរៀបចំរបៀបវារៈ និង សំណុំឯកសារផ្សេងៗសំរាប់អង្គប្រជុំរបស់ " គកជ " និង អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ " គកជ " ។

-រៀបចំកំណត់ហេតុ សេចក្តីជូនដំណឹងអង្គប្រជុំនៃ " គកជ " និង អង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ " គកជ " ដើម្បីដាក់ជូនអនុប្រធាន " គកជ " ចុះហត្ថលេខា ។

-រៀបចំរបាយការណ៍ " គកជ " ប្រចាំត្រីមាស ប្រចាំឆមាស ឬ ប្រចាំឆ្នាំ ។

-រៀបចំប្រកាសពត៌មានរបស់ " គកជ " ។

-ចូលរួមប្រជុំ " កកជ " និង អង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ " កកជ "។

-បំពេញការងារផ្សេងៗទៀតដែលប្រធាន និង អនុប្រធាន " កកជ " ប្រគល់អោយ ។

មាត្រា ១០ ._ អគ្គលេខាធិការរងនីមួយៗ បំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់អោយ ។

មាត្រា ១១ ._ សមាជិក " កកជ " មានតួនាទី និង ភារកិច្ចដូចតទៅ :

-ចូលរួមប្រជុំសាមញ្ញ និង វិសាមញ្ញនៃអង្គប្រជុំរបស់ "កកជ " ដើម្បីពិនិត្យសំរេចរាល់សំណើរបស់ស្ថាប័នដែលពាក់ព័ន្ធដល់ការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។

-សមាជិកដែលជាប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដល់ការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចលើកកម្មវិធីនយោបាយ របាយការណ៍វិធានការសំណើផ្សេងៗមក "កកជ" ដើម្បីពិនិត្យសំរេច ។

-ពិនិត្យសំរេចលើរបាយការណ៍របស់ " កកជ " ប្រចាំត្រីមាស ប្រចាំឆមាស ឬ ប្រចាំឆ្នាំ ។

មាត្រា ១២ ._ " កកជ " ត្រូវកោះប្រជុំសាមញ្ញយ៉ាងយូរ បីខែម្តង ។

មាត្រា ១៣ ._ គណៈកម្មាធិការប្រតិបត្តិនៃ " កកជ " ត្រូវកោះប្រជុំសាមញ្ញពីរសប្តាហ៍ម្តង ។

មាត្រា ១៤ ._ " កកជ " មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងស្ថាប័ន ឬ ទីប្រឹក្សាតាមការចាំបាច់ ដើម្បីចូលរួមប្រជុំ " កកជ " ឬ ប្រជុំគណៈកម្មាធិការប្រតិបត្តិ " កកជ " ។

មាត្រា ១៥ ._ អនុប្រធាន " កកជ " និងអគ្គលេខាធិការ " កកជ " មានសិទ្ធិចូលរួមប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រីតាមការអញ្ជើញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ១៦ ._ រាល់សកម្មភាពរដ្ឋបាល ថវិកាចំណាយរបស់ " កកជ " ប្រាក់បៀវត្ស និង ប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ១៧ ._ ក្នុងករណីចាំបាច់ប្រធាន " កកជ " អាចនឹងកោះប្រជុំវិសាមញ្ញរបស់ " កកជ " និង ប្រជុំវិសាមញ្ញនៃគណៈកម្មាធិការប្រតិបត្តិនៃ " កកជ " ។

មាត្រា ១៨ ._ ការប្រព្រឹត្តិទៅនៃអង្គប្រជុំរបស់ " កកជ " អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ ការរៀបចំ និង ការប្រព្រឹត្តិទៅនៃអគ្គលេខាធិការដ្ឋាន " កកជ " ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ " កកជ " ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

មាត្រា ១៩ ._ " កកជ " ប្រើត្រាទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២០ ._ រាល់អនុក្រឹត្យ និង សេចក្តីសំរេចពីមុនដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២១ ._ " កកជ " និង រាល់ក្រសួង -ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតនេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

## អនុក្រឹត្យលេខ ៣៩៦ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា ១ .-** តែងតាំងលោកស្រី ឆាន លីហូ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៣៩៧ អនក្រ.តត
## ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល
## របស់ក្រុមហ៊ុនសម្ព័ន្ធចំរុះ កាំមីនថែល

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញលក្ខន្តិកៈរបស់ក្រុមហ៊ុនសម្ព័ន្ធចំរុះ " កាំមីនថែល " ចុះហត្ថលេខា នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនសម្ព័ន្ធចំរុះ កាំមីនថែល ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-លោក ស្ទីវ យ៉ាន្ទរ តំណាងក្រុមហ៊ុន អ៊ិនដូសាត | ប្រធាន |
| ២-ឯកឧត្តម ឡុង វ៉ាន់ហុន តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៣-លោក ជា ទុចឈរា តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤-លោក ញឹក កោសល្យវិទ្យា អគ្គនាយកក្រុមហ៊ុនសម្ព័ន្ធចំរុះ កាំមីនថែល | សមាជិក |
| ៥-លោក វិចយ៉ាស ម៉ូស៊ីហ ហាន់ដាយ៉ាន់តូ តំណាងក្រុមហ៊ុន អ៊ិនដូសាត | សមាជិក |
| ៦-កញ្ញា តាន់ ស៊ីលន់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

**មាត្រា ២ .-** សមាសភាពក្រុមប្រឹក្សាភិបាលដែលមានចែងក្នុងមាត្រា ១ ខាងលើនេះ ត្រូវបានតែងតាំងសំរាប់រយៈពេល ៥ ឆ្នាំ ។

**មាត្រា ៣ .-** មុខងាររបស់ក្រុមប្រឹក្សាភិបាលត្រូវបញ្ចប់បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ដែលពិភាក្សាសំរេចលើគណនីនៃការិយបរិច្ឆេទឆ្នាំ ២០០៥ របស់ក្រុមហ៊ុន ។ សមាសភាពក្រុមប្រឹក្សាភិបាលអាចត្រូវផ្លាស់ប្តូរក្នុងគ្រប់កាលៈទេសៈដោយអនុក្រឹត្យ តាមសំណើរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រុមហ៊ុន អ៊ិនដូសាត ។

មាត្រា ៤ ._ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមហ៊ុនសម្ព័ន្ធចំរុះ "កាំមីនថែល" រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៣៩៨ អនក្រ.តត
## ស្តីពីការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយការងារ តាមលំដាប់ថ្នាក់ជូនកងឯកភាព និងនាយទាហាន ពលទាហាន នៃកងកម្លាំងវិស្វកម្ម ដែលមានស្នាដៃល្អ ក្នុងការស្តាបនាស្ពាន និងជួយសង្គ្រោះប្រជាពលរដ្ឋ ដែលរងគ្រោះ ដោយទឹកជំនន់ តាមដងផ្លូវជាតិលេខ ១ ដូចមានរាយនាមខាងក្រោមនេះ :

ក-មេដាយមាសការងារ :

-<u>ចំពោះកងឯកភាព</u> :

១-បញ្ជាការដ្ឋានវិស្វកម្ម

២-កងឯកភាព ស្ពានសាឡាងលេខ ៧១

៣-កងឯកភាព សំណង់យុទ្ធសាស្ត្រ លេខ ៧៥
៤-កងឯកភាព ប្រភពទឹកលេខ ៧៥

-ចំពោះនាយទាហាន និងពលទាហាន :

| | |
|---|---|
| ១-ឧត្តមសេនីយ៍ឯក | ម៉ុល សារឿន |
| ២-ឧត្តមសេនីយ៍ឯក | គន់ គីម |
| ៣-ឧត្តមសេនីយ៍ឯក | ជា តារា |
| ៤-ឧត្តមសេនីយ៍ឯក | ម៉ឹង សំផន |
| ៥-ឧត្តមសេនីយ៍ទោ | ខ្វាន់ ស៊ាម |
| ៦-ឧត្តមសេនីយ៍ឯទោ | ស៊ឹ សំណាង |
| ៧-ឧត្តមសេនីយ៍ត្រី | សែម សុវណ្ណនី |
| ៨-ឧត្តមសេនីយ៍ត្រី | ពៅ ផារី |
| ៩-ឧត្តមសេនីយ៍ត្រី | សួន យុន្នី |
| ១០-ឧត្តមសេនីយ៍ត្រី | ជា សុខហេង |
| ១១-វរសេនីយ៍ឯក | ម៉ម សំ |
| ១២-វរសេនីយ៍ទោ | ឡូន គន់ |
| ១៣-វរសេនីយ៍ទោ | ប៉ែន រ៉ា |
| ១៤-វរសេនីយ៍ទោ | ឡូន សំអាន |
| ១៥-វរសេនីយ៍ទោ | សាំង សាខន |
| ១៦-វរសេនីយ៍ត្រី | អ៊ី វ៉ាន់ថា |
| ១៧-វរសេនីយ៍ត្រី | ជុំ ហុន |
| ១៨-វរសេនីយ៍ត្រី | អ៊ុន ពិឌិច |
| ១៩-វរសេនីយ៍ត្រី | ណុម សាវ៉ន |
| ២០-វរសេនីយ៍ត្រី | រស់ ចិន្តា |
| ២១-វរសេនីយ៍ត្រី | ឌុន សុខា |
| ២២-វរសេនីយ៍ត្រី | សុខ ឡឿន |
| ២៣-វរសេនីយ៍ត្រី | ប៉ែន សំឡឿន |
| ២៤-អនុសេនីយ៍ឯក | ហោង បូរ៉ាវី |
| ២៥-អនុសេនីយ៍ឯក | ស៊ុន ហួយ |
| ២៦-អនុសេនីយ៍ឯក | សយ ហន |
| ២៧-អនុសេនីយ៍ឯក | ម៉ី សំបូរ |

ខ-មេដាយ ប្រាក់ការងារ ៖

| | |
|---|---|
| ១-វរសេនីយ៍ទោ | សូ សុវណ្ណមុន្នី |
| ២-វរសេនីយ៍ទោ | ខ្វាន់ ថាន |
| ៣-វរសេនីយ៍ត្រី | ឈ្លាង វណ្ណរិទ្ធ |
| ៤-វរសេនីយ៍ត្រី | ស៊ិន ស័ក្តិ |
| ៥-វរសេនីយ៍ត្រី | យ៉ៃ យ៉ាន |
| ៦-វរសេនីយ៍ត្រី | ឃ្លោក សារី |
| ៧-វរសេនីយ៍ត្រី | ស៊ូ សុវណ្ណ |
| ៨-អនុសេនីយ៍ឯក | កែវ រ៉េន |
| ៩-អនុសេនីយ៍ឯក | យិន សុន្ទរៈ |
| ១០-អនុសេនីយ៍ឯក | រស់ អ៊ឹម |
| ១១-អនុសេនីយ៍ឯក | លី វណ្ណារ៉ា |
| ១២-អនុសេនីយ៍ឯក | ប៉ែន វិបុល |
| ១៣-អនុសេនីយ៍ឯក | នង សុភ័ក្ត្រា |
| ១៤-អនុសេនីយ៍ឯក | ប៉ែន សំអាត |
| ១៥-អនុសេនីយ៍ឯក | ទី សារ៉ាន់ |
| ១៦-អនុសេនីយ៍ឯក | ហ៊ឹម សំអឿន |
| ១៧-អនុសេនីយ៍ឯក | ទួន សាមីឌី |
| ១៨-អនុសេនីយ៍ឯក | អ៊ិត ស៊ីសូដា |
| ១៩-អនុសេនីយ៍ឯក | យូ ចាន់រិទ្ធី |
| ២០-អនុសេនីយ៍ឯក | ខ្វាន់ សាម៉ន |
| ២១-អនុសេនីយ៍ឯក | តាន់ សាលី |
| ២២-អនុសេនីយ៍ឯក | ពុត សារ៉ាត់ |
| ២៣-អនុសេនីយ៍ទោ | យស់ បូណាត |
| ២៤-អនុសេនីយ៍ទោ | គង់ សុផាត |
| ២៥-អនុសេនីយ៍ទោ | ស្រី មន |
| ២៦-អនុសេនីយ៍ទោ | នេត្រ សាខន |
| ២៧-អនុសេនីយ៍ទោ | យួន សាម៉េន |
| ២៨-អនុសេនីយ៍ទោ | ឡាច សារ៉ែន |

គ-មេដាយសេរីវឌ្ឍ ការងារ :

១-អនុសេនីយ៍ត្រី គង់ មុនី
២-អនុសេនីយ៍ត្រី ម៉ី សុខអ៊ីម
៣-អនុសេនីយ៍ត្រី កុល វុត្ថា
៤-អនុសេនីយ៍ត្រី អ៊ី សំនៀង
៥-អនុសេនីយ៍ត្រី សូ សុធា
៦-អនុសេនីយ៍ត្រី សុខ ញ៉ាញ់
៧-អនុសេនីយ៍ត្រី ហ៊ុល ជឿន
៨-នាយចំណង់ ផៃ ស៊ីចាន់
៩-នាយចំណង់ សែម ដេត
១០-នាយចំណង់ រស់ សុខឃឿន
១១-នាយចំណង់ ចក់ ចក
១២-នាយចំណង់ ម៉ាស ចាន់
១៣-នាយចំណង់ កើត សំរេច
១៤-នាយចំណង់ កង សុផាត
១៥-នាយចំណង់ ខួន កណ្ណារិទ្ធ
១៦-នាយចំណង់ ប៊ុត គន្ធា
១៧-ព្រិន្ទបាលឯក ញ៉ៀម សាមឿន
១៨-ព្រិន្ទបាលឯក ប៉ុល ធឿន
១៩-ព្រិន្ទបាលឯក ប៊ូ សុខា
២០-ព្រិន្ទបាលឯក យ៉ៃ ចាន់
២១-ព្រិន្ទបាលឯក ម៉ែន សារិទ្ធ
២២-ព្រិន្ទបាលឯក ហួន សារ៉ែន
២៣-ព្រិន្ទបាលឯក ជុំ រឿន
២៤-ព្រិន្ទបាលឯក ស៊ឹម ស៊ីដា
២៥-ព្រិន្ទបាលឯក សន ធូ
២៦-ព្រិន្ទបាលឯក កែវ ពៅ
២៧-ព្រិន្ទបាលឯក អួន កុសល
២៨-ព្រិន្ទបាលឯក សៃ ភិរុណ
២៩-ព្រិន្ទបាលឯក ចាន់ ធិន

៣០-ព្រិន្ទបាលឯក គង់ វណ្ណា
៣១-ព្រិន្ទបាលឯក ហែម វីរៈ
៣២-ព្រិន្ទបាលឯក យក់ ជិនហ៊ួរ
៣៣-ព្រិន្ទបាលទោ ស្វាយ សារី
៣៤-ព្រន្ទបាលទោ ព្រាប សុវណ្ណនី
៣៥-ព្រន្ទបាលទោ ឆូ សារ៉ុន
៣៦-ព្រន្ទបាលទោ គឹម ចន្ធី
៣៧-ព្រន្ទបាលទោ ហែម សម្បត្តិ
៣៨-ព្រន្ទបាលទោ ចៀប សាក់និមល
៣៩-ព្រន្ទបាលទោ ស៊ូ គោគ
៤០-ព្រន្ទបាលទោ យ៉ាត វិបុល
៤១-ពលបាលឯក ម៉ម ឡុល
៤២-ពលបាលឯក ទេព ថា
៤៣-ពលបាលឯក នួវ ខន
៤៤-ពលបាលឯក ប៉ែន សុភ័ក្ត្រ
៤៣-ពលបាលឯក រិន រ៉ែន
៤៦-ពលបាលឯក គោគ ផាត់
៤៧-ពលបាលឯក គិន រីម
៤៨-ពលបាលឯក សឿន ស៊ា
៤៩-ពលបាលឯក ចាន់ ធី
៥០-ពលបាលឯក ខាន់ ចាន់ស៊ី
៥១-ពលបាលទោ សូ សារឿន
៥២-ពលបាលទោ ហៀង សុខា
៥៣-ពលបាលទោ យា ម៉ៅ
៥៤-ពលបាលទោ រដ្ឋ សារិន
៥៥-ពលបាលទោ ឆាង សារឿន
៥៦-ពលបាលទោ ឆាង ម៉ុនធឿន
៥៧-ពលបាលត្រី សៅ សំអូន
៥៨-ពលបាលត្រី អ៊ុង សុខុន
៥៩-នាយឯក នួន សុផាន

| | |
|---|---|
| ៦០-នាយឯក | ម៉ែន ស្មឹតី |
| ៦១-នាយឯក | ឆូច ពៅ |
| ៦២-នាយឯក | ស្វស ចាន់ |
| ៦៣-នាយឯក | ស៊ឹម ទី |
| ៦៤-នាយឯក | ចាន់ ឆិត្យ |
| ៦៥-នាយឯក | ឈន ឈឹម |
| ៦៦-នាយឯក | ឡុង ផលតារ៉ា |
| ៦៧-នាយឯក | ហាក់ តាព |
| ៦៨-នាយឯក | ពិន វណ្ណា |
| ៦៩-នាយឯក | សាន្ត សុផាត |
| ៧០-នាយឯក | ម៉ែន សុតាព |
| ៧១-នាយឯក | កែវ ឌឹម |
| ៧២-នាយឯក | ម៉ុញ វិបុល |
| ៧៣-នាយឯក | ឈុក សកល |

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៣៩៩ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោក Carson Harte នាយកអង្គការ Cambodia Trust មកពីប្រទេសអៀរឡង់ខាងជើង នៃចក្រភពអង់គ្លេស ដែលបានខិតខំរែអង្គាសថវិកាបានចំនួន ៥.៤០០.០០០ ដុល្លារអាមេរិក យកមកជួយទ្រទ្រង់ការចំណាយសំរាប់ដំណើរការមជ្ឈមណ្ឌលស្តារកាយសម្បទា និងសាលាបច្ចេកទេសផលិតអវយវៈ និងរណប នៅក្នុងមន្ទីរពេទ្យកាល់ម៉ែត្រ ( CSPO ) មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មនៅក្រុងព្រះសីហនុ ខេត្តកំពង់ឆ្នាំង និងរោងជាងនៅមជ្ឈមណ្ឌល ៣១៧ ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៤០០ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរជន ០៥ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសំណង់សាធារណៈផ្សេងៗ នៅទីរួមខេត្តកំពង់ចាមដូចមាននាមខាងក្រោមនេះ ៖

**ក-មេដាយមាសស្ថាបនាជាតិ :**

-លោក ចាន អ៊ីហ្វីន បរិច្ចាគប្រាក់ ១០.២០០ ដុល្លារអាមេរិក

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក ម៉ូ គឹមថេង បរិច្ចាគប្រាក់ ៥.០០០ ដុល្លារអាមេរិក

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោក ឈិន ឃុនលី បរិច្ចាគប្រាក់ ២.៧០០ ដុល្លារអាមេរិក

២-លោក ងួន ម៉ិនឡើន បរិច្ចាគប្រាក់ ៤.៨០០.០០០ រៀល

៣-លោក លុយ ម៉ិនឃុន បរិច្ចាគប្រាក់ ១.៥០០ ដុល្លារមេអារិក

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៤០១ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោក **ទេដា ឃាត្តូ** សប្បុរសជនជប៉ុន ដែលបាន ផ្តល់អំណោយជាអាគារសិក្សាមួយខ្នង មាន ០៥ បន្ទប់ បំពាក់ដោយសម្ភារៈសិក្សាគ្រប់គ្រាន់រួមទាំងបង្គន់ អនាម័យ ក្លោងទ្វារ អណ្តូងទឹក និងផងទង់ជាតិ មានតម្លៃជាទឹកប្រាក់សរុប ចំនួន **២៥.៧៩១** ដុល្លារ អាមេរិក ជូនសាលាបឋមសិក្សា ទទឹងថ្ងៃ ក្នុងឃុំបឹងទូក ស្រុកកំពត ខេត្តកំពត ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្ត កំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០០**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៩០២ អនក្រ.តត**

**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី **៣០** ខែ **វិច្ឆិកា** ឆ្នាំ **១៩៩៨** ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី **២០** ខែ **កក្កដា** ឆ្នាំ **១៩៩៤** ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី **០៥** ខែ **តុលា** ឆ្នាំ **១៩៩៥** ស្តីពី ការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសមាគម SOTOSHU TOSHIGI KEN INTER NATIONAL VOLUNTEER ASSOCIATION នៃប្រទេសជប៉ុនដែលបានធ្វើអំណោយអាគារសិក្សា មួយខ្នង ជូនសាលាបឋមសិក្សាកោះខ្សាយ ក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង មានតម្លៃជាទឹកប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៩០៣ អនក្រ.តត**

**ស្តីពីការជូនមេដាយសហមេត្រី**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយ ធិបឌិន្ទ សហមេត្រី ជូនលោក Moncef BEL HAJ AMOR សញ្ជាតិទុយនីស៊ី ទីប្រឹក្សាជាន់ខ្ពស់អមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងការជួយកែទំរង់ និងអភិវឌ្ឍន៍ការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ ១៩៩១ រហូតដល់ខែ វិច្ឆិកា ឆ្នាំ ២០០០ ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

# អនុក្រឹត្យលេខ ៩០៧ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- តាមសំណើរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងលោក ឡេង សុជា ជាអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការសកម្មភាពកំចាត់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការ មានឋានៈស្មើនឹងអគ្គនាយករង ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យលេខ ៨០៥ អនក្រ.តត
# ស្តីពីការតែងតាំង សមាជិក
# នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការ បង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

**សំរេច**

**មាត្រា ១ .-**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសមាសភាពដូចតទៅ ៖

-ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធាន

-ឯកឧត្តម ឈា សុខ រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន

-ឯកឧត្តម លី ធុច រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន

-ឯកឧត្តម នី យ៉ាទ រដ្ឋលេខាធិការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិកអចិន្ត្រៃយ៍ និង ជាអគ្គលេខាធិការនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ឯកឧត្តម ថ្រី សុខា រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ សមាជិក

-ឯកឧត្តម ចាយ សាំងយុន រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ សមាជិក

-ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

-ឯកឧត្តម ឆាន់ សាផាន រដ្ឋលេខាធិការ នៃក្រសួងបរិស្ថាន សមាជិក

-ឯកឧត្តម ទៅ ពិន រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម សមាជិក

-ឯកឧត្តម អ៊ឺ ដារ៉ាឌុច រដ្ឋលេខាធិការ នៃក្រសួងពត៌មាន សមាជិក

-ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ សមាជិក

-អ្នកអង្គម្ចាស់ ស៊ីសុវត្ថ ប៉ាណារ៉ាស៊ីរីវុឌ្ឍ រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សមាជិក

-ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការ នៃក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

-ឯកឧត្តម អ៊ិត ប្រាង រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

-លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សមាជិក

-ឯកឧត្តម អ៊ូ ឱ្យហាត រដ្ឋលេខាធិការ នៃក្រសួងផែនការ សមាជិក

-ឯកឧត្តម សេង លឹមនៅ អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

-ឯកឧត្តម សួន សុធី អគ្គលេខាធិការ នៃគណៈកម្មការជាតិវិនិយោគកម្ពុជា សមាជិក

មាត្រា ២ ._ បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ស្ថាប័ន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៥០៦ អនក្រ.តត

## ស្តីពីការតែងតាំង សមាជិកនៃក្រុមប្រឹក្សា អភិវឌ្ឍន៍សង្គមកិច្ច

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការ បង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច
- តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

**សំរេច**

មាត្រា ១ ._

ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានសមាសភាពដូចតទៅ ៖

១-ឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រី ក្រសួងផែនការ ប្រធាន

២-ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣-ឯកឧត្តម អ៊ូ ឱរ៉ាត រដ្ឋលេខាធិការក្រសួងផែនការ អនុប្រធានអចិន្ត្រៃយ៍

៤-ឯកឧត្តម ចាន់ តុងអ៊ីវ រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៥-ឯកឧត្តម លី ធុជ រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៦-ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិក

៧-ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៨-លោកជំទាវ អ៊ិង កន្ថាផាវី រដ្ឋលេខាធិការក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន សមាជិក

៩-ឯកឧត្តម នឹម ថូត រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក

១០-ឯកឧត្តម នូ សាំងខន រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក

១១-ឯកឧត្តម គឹម សយសាម៉ាឡែន អនុរដ្ឋលេខាធិការ ក្រសួងផែនការ អគ្គលេខាធិការ

១២-ឯកឧត្តម សេង លឹមនៅ អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣-ឯកឧត្តម ឈៀង យ៉ាណារ៉ា អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

មាត្រា ២ ._ បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការគ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ព្រមទាំងសមាជិកទាំងអស់នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ដូចមានចែងក្នុងមាត្រាខាងលើ ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

សមាជិកអចិន្ត្រៃយ៍

ហត្ថលេខា

សុខ អាន

★★★

## អនុក្រឹត្យលេខ ៩០៧ អនក្រ.តត
## ស្តីពីការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់មេដាយការងារ ថ្នាក់សំរិទ្ធ ជូនដល់កងជីវពលចំនួន ៣២.១១០ នាក់ដែលមានស្នាដៃក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ។

**មាត្រា ២ .-** បញ្ជីរាយនាមកងជីវពល ដូចមានចែងក្នុងមាត្រា ១ ត្រូវបានភ្ជាប់ដោយឧបសម្ព័ន្ធ ដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ឧបសម្ព័ន្ធទី ១ | : | រាជធានីភ្នំពេញ | ចំនួន | ៩៥៧ នាក់ |
| ឧបសម្ព័ន្ធទី ២ | : | ខេត្តកណ្តាល | ចំនួន | ១.២៨៩ នាក់ |
| ឧបសម្ព័ន្ធទី ៣ | : | ខេត្តកំពង់ស្ពឺ | ចំនួន | ១.៧០៦ នាក់ |
| ឧបសម្ព័ន្ធទី ៤ | : | ខេត្តកំពង់ឆ្នាំង | ចំនួន | ១.៨១៥ នាក់ |
| ឧបសម្ព័ន្ធទី ៥ | : | ខេត្តកំពង់ចាម | ចំនួន | ២.៥២៨ នាក់ |
| ឧបសម្ព័ន្ធទី ៦ | : | ខេត្តព្រៃវែង | ចំនួន | ៧៥៨ នាក់ |
| ឧបសម្ព័ន្ធទី ៧ | : | ខេត្តស្វាយរៀង | ចំនួន | ៦៨៧ នាក់ |
| ឧបសម្ព័ន្ធទី ៨ | : | ខេត្តក្រចេះ | ចំនួន | ១.០១៦ នាក់ |
| ឧបសម្ព័ន្ធទី ៩ | : | ខេត្តពោធិសាត់ | ចំនួន | ១.៩០៣ នាក់ |
| ឧបសម្ព័ន្ធទី ១០ | : | ខេត្តបាត់ដំបង | ចំនួន | ៣.៣១៩ នាក់ |
| ឧបសម្ព័ន្ធទី ១១ | : | ខេត្តបន្ទាយមានជ័យ | ចំនួន | ១.៨២៥ នាក់ |
| ឧបសម្ព័ន្ធទី ១២ | : | ក្រុងប៉ៃលិន | ចំនួន | .២០៤ នាក់ |
| ឧបសម្ព័ន្ធទី ១៣ | : | ខេត្តតាកែវ | ចំនួន | ១.៣៦៦ នាក់ |
| ឧបសម្ព័ន្ធទី ១៤ | : | ខេត្តកំពត | ចំនួន | ១.៧៤៧ នាក់ |
| ឧបសម្ព័ន្ធទី ១៥ | : | ក្រុងព្រះសីហនុ | ចំនួន | ៥០០ នាក់ |
| ឧបសម្ព័ន្ធទី ១៦ | : | ខេត្តកោះកុង | ចំនួន | ៥៧១ នាក់ |
| ឧបសម្ព័ន្ធទី ១៧ | : | ក្រុងកែប | ចំនួន | ៩១៦ នាក់ |
| ឧបសម្ព័ន្ធទី ១៨ | : | ខេត្តកំពង់ធំ | ចំនួន | ២.២៩៦ នាក់ |
| ឧបសម្ព័ន្ធទី ១៩ | : | ខេត្តសៀមរាប | ចំនួន | ២.៦០៩ នាក់ |
| ឧបសម្ព័ន្ធទី ២០ | : | ខេត្តព្រះវិហារ | ចំនួន | ២.២២៥ នាក់ |
| ឧបសម្ព័ន្ធទី ២១ | : | ខេត្តឧត្តរមានជ័យ | ចំនួន | ១.១៧០ នាក់ |
| ឧបសម្ព័ន្ធទី ២២ | : | ខេត្តស្ទឹងត្រែង | ចំនួន | ៧៩២ នាក់ |
| ឧបសម្ព័ន្ធទី ២៣ | : | ខេត្តមណ្ឌលគិរី | ចំនួន | ៣៨៤ នាក់ |

ឧបសម្ព័ន្ធទី ២៤ : ខេត្តរតនៈគិរី ចំនួន ៦៤២ នាក់

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០០

### សេចក្តីសំរេចលេខ ៦៥ សសរ

### ស្តីពីការបង្កើតលេខាធិការដ្ឋាន របស់គណៈកម្មការចំរុះអន្តរក្រសួង ដើម្បីតាមដាន និង បង្ក្រាបក្រុមភេរវកម្មប្រដាប់អាវុធ

***

### គណៈកម្មការចំរុះអន្តរក្រសួង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ២០/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៦៤ សសរ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីតាមដាន និង បង្ក្រាបក្រុមភេរវកម្មប្រដាប់អាវុធ
- យោងតាមសំណូមពរចាំបាច់របស់គណៈកម្មការចំរុះអន្តរក្រសួង

### សំរេច

ប្រការ ១ : បង្កើតលេខាធិការដ្ឋានមួយ ដើម្បីជួយការងាររបស់គណៈកម្មការចំរុះអន្តរក្រសួងសំរាប់តាមដាន និង បង្ក្រាបក្រុមភេរវកម្មប្រដាប់អាវុធដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ ប្រធាន

២-ឯកឧត្តម ឧត្តមសេនីយ៍ឯក មាស សុភា អគ្គបញ្ជាការរងកងយោធពលខេមរភូមិន្ទ អនុប្រធា

៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អនុប្រធាន
៤-ឯកឧត្តម ពេជ្រ ម៉ុនធិន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក
៥-ឯកឧត្តម អន្ទ ចន្ទ្រាទ្ធារា រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ សមាជិក
៦-ឯកឧត្តម ឡុង វិសាលោ អនុរដ្ឋលេខាធិការ ក្រសួងការបរទេស សមាជិក
៧-ឯកឧត្តម ខ្ញុំម យិនឡៀង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក
៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ល់ រឿម ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក
៩-ឯកឧត្តម ឧត្តមសេនីយ៍ទោ យូ ស៊ុនឡុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក
១០-ឯកឧត្តម ឧត្តមសេនីយ៍ទោ នេត្រ សាវឿន ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ សមាជិក
១១-លោក ឧត្តមសេនីយ៍ត្រី សុខ ផល ប្រធាននាយកដ្ឋានពត៌មានទូទៅ សមាជិក
១២-លោក ឧត្តមសេនីយ៍ត្រី គន្ធ សំអឿន ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម សមាជិក
១៣-លោក ឧត្តមសេនីយ៍ត្រី ម៉ៅ ច័ន្ទតារា ប្រធានសេនាធិការ សមាជិក
១៤-លោក ឧត្តមសេនីយ៍ត្រី ចន្ទ្រា ពិសេន មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
១៥-លោក ឧត្តមសេនីយ៍ត្រី ជុំ ឃាត់ ប្រធានការិយាល័យទី២កងទ័ពជើងគោក សមាជិក

**ប្រការ ២ :** លេខាធិការដ្ឋានមានភារកិច្ចដូចតទៅ :

-ប្រមែប្រមូលឯកសារពាក់ព័ន្ធនឹងអំពើភេរវកម្មប្រដាប់អាវុធ ពីគ្រប់ស្ថាប័នមានសមត្ថកិច្ច ពិនិត្យពិចារណា បូកសរុបធ្វើការសន្និដ្ឋានវាយតម្លៃ បែងចែកសមាសភាពពាក់ព័ន្ធជាយោធិនជាកងរាជអាវុធហត្ថ ជានគរបាលជាតិ និង ជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈដាក់ជូនគណៈកម្មការចំរុះពិនិត្យសំរេចអោយស្របតាមនីតិវិធីច្បាប់ ។

-រៀបចំសំណុំឯកសារ វត្ថុតាង និង សមាសភាពពាក់ព័ន្ធនឹងសកម្មភាពភេរវកម្មប្រដាប់អាវុធ ដើម្បីដាក់ជូនគណៈកម្មការចំរុះពិនិត្យសំរេច មុននឹងបញ្ជូនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ ។

-លើកគំនិតផ្តើម អំពីវិធានការទប់ស្កាត់ បង្ការ បង្ក្រាបសកម្មភាពភេរវកម្មប្រដាប់អាវុធស្វែងរកចាប់ខ្លួនសមាសភាពការពាក់ព័ន្ធ ដើម្បីដាក់ជូនគណៈកម្មការចំរុះ ពិនិត្យសំរេច ។

-លើកគំនិតផ្តើម ក្នុងការដោះស្រាយសកម្មភាព និង ពួកភេរវកម្មប្រដាប់អាវុធ ដែលមានការទាក់ទងជាមួយបណ្តាប្រទេស ដើម្បីដាក់ជូនគណៈកម្មការចំរុះពិនិត្យសំរេច ។

-រៀបចំកម្មវិធីប្រជុំ ធ្វើលិខិតអញ្ជើញ គ្រប់សមាជិកគណៈកម្មការចំរុះទាំងអស់ និង គ្រប់គ្រងឯកសារនានា តាមការសំរេចរបស់ប្រធានគណៈកម្មការចំរុះ ។

**ប្រការ ៣ :** បង្កើតក្រុមការងារចំណុះលេខាធិការដ្ឋាន ដែលមានសមាសភាព និង ភារកិច្ចដូចតទៅ :

១-**ក្រុមការងារយោធា - កងរាជអាវុធហត្ថ** : រួមមានសមាសភាព :

-ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ល់ រឿម ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ប្រធាន
-ឯកឧត្តម ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អនុប្រធាន

-លោក ឧត្តមសេនីយ៍ត្រី ខឿ ពិសេន មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

-លោក ឧត្តមសេនីយ៍ត្រី ជុំ ឈាត់ ប្រធានការិយាល័យទី២ សមាជិក

ក្រុមការងារនេះមានភារកិច្ចប្រមែប្រមូល ឯកសារពាក់ព័ន្ធនឹងអំពើភេរវកម្មប្រដាប់អាវុធដែលទាក់ទងទៅនឹងសមាសភាពជាយោធិន កងរាជអាវុធហត្ថ ហើយធ្វើជាតារាងបញ្ជីឈ្មោះរូបថតភេរវករ ឬ ជនជាប់សង្ស័យ ។ ផ្ដើមមតិបែងចែកសមាសភាពទាំងនោះ អោយសមស្របទៅតាមនីតិវិធីច្បាប់ ។ លើកយោបល់បន្តការស្រាវជ្រាវ ស្វែងរកចាប់ខ្លួន សមាសភាពពាក់ព័ន្ធ រៀបចំកសាងសំណុំរឿងបញ្ជូនទៅតុលាការបន្ទាប់ពីមានការពិនិត្យសំរេចពីគណៈកម្មការចំរុះ ។ បូកសរុប និង ធ្វើការសន្និដ្ឋានវាយតម្លៃតាមដំណាក់ការនីមួយៗដាក់ជូន ប្រធានលេខាធិការដ្ឋាន ដើម្បីរាយការណ៍ជូនប្រធានគណៈកម្មការចំរុះ ។

**២-ក្រុមការងារនគរបាលជាតិ :** រួមមានសមាសភាព :

-ឯកឧត្តម ឧត្តមសេនីយ៍ទោ **យូ ស៊ុនឡុង** ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី ប្រធាន

-ឯកឧត្តម ឧត្តមសេនីយ៍ទោ **នេត្រ សាវឿន** ប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ អនុប្រធាន

-លោក ឧត្តមសេនីយ៍ត្រី **ម៉ូ លីជា** អនុប្រធានទី១នាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ សមាជិក

-លោក ឧត្តមសេនីយ៍ត្រី **ម៉ៅ ច័ន្ទតារា** ប្រធានសេនាធិការដ្ឋាន សមាជិក

-លោក ឧត្តមសេនីយ៍ត្រី **សុខ ផល** ប្រធាននាយកដ្ឋានពត៌មានទូទៅ សមាជិក

-លោក ឧត្តមសេនីយ៍ត្រី **គន្ធ សំអឿន** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម សមាជិក

ក្រុមការងារនេះមានភារកិច្ច ប្រមែប្រមូលឯកសារពាក់ព័ន្ធនឹងអំពើភេរវកម្មប្រដាប់អាវុធដែលទាក់ទងទៅនឹងសមាសភាពជានគរបាលជាតិ ធ្វើតារាងបញ្ជីឈ្មោះ រូបថតភេរវករ ឬជនជាប់សង្ស័យ ។ ផ្ដើមមតិបែងចែកសមាសភាពទាំងនោះអោយសមស្របតាមនីតិវិធីច្បាប់ ។ លើកយោបល់ស្នើសុំបន្តការស្រាវជ្រាវ ស្វែងរកចាប់ខ្លួនសមាសភាពពាក់ព័ន្ធ រៀបចំកសាងសំណុំរឿងបញ្ជូនទៅតុលាការបន្ទាប់ពីមានការពិនិត្យសំរេចពីគណៈកម្មការចំរុះ ។ បូកសរុប និង ធ្វើការសន្និដ្ឋានវាយតម្លៃតាមដំណាក់ការនីមួយៗដាក់ជូនប្រធាន លេខាធិការដ្ឋានជ្រាប ដើម្បីរាយការណ៍ជូនប្រធានគណៈកម្មការចំរុះ ។

**៣-ក្រុមការងារមន្ត្រីរាជការក្នុងមុខងារសាធារណៈ :** ឯកឧត្តម **ពេជ្រ ប៊ុនធិន** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ទទួលខុសត្រូវពិនិត្យពិចារណា និងផ្ដើមយោបល់បែងចែកសមាសភាពមន្ត្រីរាជការក្នុងមុខងារសាធារណៈ ដែលមានការពាក់ព័ន្ធទៅនឹងសកម្មភាព និង អង្គការចាត់តាំងភេរវកម្មប្រដាប់អាវុធ ដែលទទួលបានពីក្រុមការងារទី១ និងទី២ ផ្ដល់ជូនអោយសមស្របទៅតាមនីតិវិធីច្បាប់ ដើម្បីដាក់ជូនគណៈកម្មការចំរុះពិនិត្យសំរេច ។

**៤-ក្រុមការងារការបរទេស :** ឯកឧត្ត **ឡុង វិសាលោ** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទួលខុសត្រូវក្នុងការផ្ដើមគំនិតយោបល់ជូនគណៈកម្មការចំរុះ ក្នុងការធ្វើសហ

ប្រតិបត្តិការចរចា និង សំរបសំរួលជាមួយបណ្តាប្រទេសដែលពួកភេរវករប្រដាប់អាវុធបាន និង កំពុងស្នាក់នៅ ដើម្បីចាប់បញ្ជូនតាមផ្លូវច្បាប់ប្រគល់មកអាជ្ញាធរមានសមត្ថកិច្ចកម្ពុជា ដោះស្រាយ ឬ ចាត់ការកាត់ទោសតាមផ្លូវច្បាប់របស់បណ្តាប្រទេសទាំងនោះ ។

៥-**ក្រុមការងារយុត្តិធម៌** : ឯកឧត្តម **អន្ត ចន្ទមុនីរ៉ា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ទទួលខុសត្រូវពិនិត្យ ពិចារណា និង ផ្តល់យោបល់ធ្វើយ៉ាងណាអោយក្រុមការងារទាំងអស់អនុវត្តបានសមស្របតាមនីតិវិធីច្បាប់ ។

៦-**អ្នកនាំពាក្យ** : ប្រគល់ភារកិច្ចជូនឯកឧត្តម **ខៀវ ឃិនធៀង** ទទួលខុសត្រូវជាអ្នកនាំពាក្យរបស់គណៈកម្មការចំរុះ ។

**ប្រការ ៤ :** ក្រុមការងារនីមួយៗ ត្រូវម្ចាស់ការបំពេញភារកិច្ចរបស់ខ្លួនអោយបានសំរេច ។ ក្នុងករណីនេះមានសិទ្ធិប្រើប្រាស់កម្លាំង និង មធ្យោបាយក្រោមឱវាទរបស់ក្រុមការងារនីមួយៗ និង មានសិទ្ធិស្នើសុំបញ្ជូនដល់ក្រសួងស្ថាប័នពាក់ព័ន្ធ សុំផ្តល់កិច្ចសហប្រតិបត្តិការ ឬ សុំឯកសារផ្សេងៗដែលចាំបាច់ពាក់ព័ន្ធដល់សកម្មភាពភេរវកម្មប្រដាប់អាវុធ ។

**ប្រការ ៥ :** ប្រធានលេខាធិការដ្ឋានមានភារកិច្ចដូចតទៅ :

-ដឹកនាំជំរុញក្រុមការងារទាំងអស់អោយបំពេញភារកិច្ចរបស់ខ្លួនបានល្អ និង មានប្រសិទ្ធិភាព ។

-ចាត់ចែងរៀបចំកម្មវិធី និង ផលិតឯកសារគ្រប់ការប្រជុំរបស់គណៈកម្មការចំរុះ ។

-ចេញលិខិតអញ្ជើញសមាជិកគណៈកម្មការចំរុះ និងសមាសភាពពាក់ព័ន្ធមកចូលរួមប្រជុំ ។

-ចាត់ចែងអោយប្រមូលផ្តុំ និង ចងក្រងរក្សាទុកគ្រប់ឯកសារទាំងអស់ពាក់ព័ន្ធនឹងភេរវកម្មប្រដាប់អាវុធ ។

-ចាត់ចែងបញ្ជូនសំណុំរឿង វត្ថុតាងផ្សេងៗ និង ជនល្មើសទៅតុលាការ ដើម្បីពិនិត្យ និងវិនិច្ឆ័យទោសក្រោយពេលគណៈកម្មការចំរុះពិនិត្យសំរេចរួច ។

-បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការចំរុះអន្តរក្រសួងប្រគល់អោយ ។

**ប្រការ ៦ :** លេខាធិការដ្ឋានមានសិទ្ធិប្រើត្រាបេស់អគ្គនាយកដ្ឋាននគរបាលជាតិ លើឯកសារផ្លូវការ ។

**ប្រការ ៧ :** សេចក្តីសំរេចនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ប្រធានគណៈកម្មការចំរុះអន្តរក្រសួង

ហត្ថលេខា និងត្រា

**ស ខេង**

★★★

# II- ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០

### ប្រកាសលេខ ៨៣៧ សហវ

### ស្ដីពីការកំណត់ប្រភេទទំនិញ និងកំរៃសេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូល ផ្ទុកក្នុងកុងតឺន័រតាមប្រព័ន្ធ TC-SCAN

****

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង មានការកែប្រែក្នុងច្បាប់ ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងកាប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្ដីជូនដំណឹងលេខ ៨៤៩ សជណ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីការឯកភាពជាគោលការណ៍អោយក្រុមហ៊ុន SINH DAI

INVESTMENT Co., LTD បង្កើតស្ថានីយ៍ត្រួតពិនិត្យកុងតឺន័រ ដោយប្រព័ន្ធ TC-SCAN នៅកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ

- យោងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០០ លើលិខិតលេខ ២១៧៥ សហវ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** កំណត់បណ្តាប្រភេទទំនិញនាំចេញ នាំចូលដែលចាំបាច់ត្រូវដាក់អោយត្រួតពិនិត្យដោយប្រព័ន្ធ TC-SCAN ដូចខាងក្រោម :

-**ចំពោះការនាំចេញ :** រាល់ទំនិញទាំងអស់ដែលផ្ទុកក្នុងកុងតឺន័រ លើកលែងតែកុងតឺន័រទទេ ។

-**ចំពោះការនាំចូល :** រាល់ទំនិញទាំងអស់ដែលផ្ទុកក្នុងកុងតឺន័រ លើលែងតែក្នុងករណីណាមួយដូចខាងក្រោម :

-ទំនិញប្រភេទខ្លះដែលមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច យល់ថាត្រូវត្រួតពិនិត្យលំអិត និងដែលអាចខូចគុណភាពដោយសារការប្រើប្រាស់ប្រព័ន្ធនេះ ហើយពុំចាំបាច់ឆ្លងកាត់ប្រព័ន្ធនេះ ។

-កុងតឺន័រទទេ ។

**ប្រការ ២ :** កំណត់កំរៃសេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូល ដូចចែងក្នុងប្រការ ១ ខាងលើ ដូចខាងក្រោម :

-កុងតឺន័រមានទំនិញ ទំហំ ៤០ ហ្វីត ឡើងទៅ : កំណត់កំរៃ ៨០ USD ( ប៉ែតសិប ) ក្នុងមួយកុងតឺន័រ ។

-កុងតឺន័រមានទំនិញទំហំ ២០ ហ្វីត : កំណត់កំរៃ ៥០ USD ( ហាសិប ) ក្នុងមួយកុងតឺន័រ ។

**ប្រការ ៣ :** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីពេលដាក់អោយដំណើរការជាផ្លូវការនៃស្ថានីយ៍ត្រួតពិនិត្យកុងតឺន័រតាមប្រព័ន្ធ TC-SCAN ខាងលើ ក្នុងបរិវេណកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ។

**ប្រការ ៤ :** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ និងត្រូវចាត់ទុកជានិរាករណ៍ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
**គាត ឈន់**

★★★